ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍បូកសរុប

## សកម្មភាព និងលទ្ធផលការងារ បង្ការ ទប់ស្កាត់ និង បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៣ និងទិសដៅឆ្នាំ២០១៤




គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ

# អារម្ភកថា

## ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជនរួមជាតិជាទីស្នេហា

ការរៀបចំបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់នីតិកាលទី៥នៃរដ្ឋសភារបស់ព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ បានប្រព្រឹត្តទៅដោយរលូន គ្មានអំពើហិង្សា ព្រមទាំងទទួលបានការគាំទ្រ និងវាយតម្លៃខ្ពស់ពីសហគមន៍ជាតិ និងអន្តរជាតិ ។ ឯការរៀបចំនិងការប្រព្រឹត្តទៅនៃរដ្ឋសភា និងរាជរដ្ឋាភិបាល ក៏បានអនុវត្តក្រោមរដ្ឋធម្មនុញ្ញ និងច្បាប់ជាតិដោយមិនមានការរាំងស្ទះ ។ លើសពីនេះទៅទៀត វិបត្តិសេដ្ឋកិច្ចពិភពលោក គ្រោះធម្មជាតិ ការដោះស្រាយបញ្ហាប្រាសាទព្រះវិហារ និងបញ្ហាសង្គមមួយចំនួន ពុំមែនជាឧបសគ្គចំពោះកិច្ចខិតខំប្រឹងប្រែងរបស់យើងឡើយ ។ ព្រះរាជាណាចក្រកម្ពុជានៅតែរក្សាបានយ៉ាងខ្ជាប់ខ្ជួននូវសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងដោះស្រាយបានរាល់បញ្ហាដោយរលូន ដែលនាំមកនូវទំនុកចិត្តដល់ប្រជាពលរដ្ឋ វិនិយោគិន ជាពិសេសភ្ញៀវទេសចរណ៍ដែលនៅតែបន្តកើនឡើងគួរជាទីមោទនៈ ហើយប្រជាពលរដ្ឋកម្ពុជាក៏បាន និងកំពុងតែបង្កបង្កើនផលយ៉ាងសកម្ម និងទទួលបានទិន្នផលខ្ពស់គួរឲ្យកត់សម្គាល់ ដែលធ្វើឲ្យមានចំណូលសេដ្ឋកិច្ចជាតិល្អប្រសើរ និងនៅតែរក្សាបាននូវកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ ក្នុងរង្វង់ប្រាំពីរភាគរយដដែល ។

ទោះបីជាយ៉ាងនេះក្តី ក៏មានប្រជាពលរដ្ឋ ទាំងស្ត្រី បុរស និងយុវវ័យពេញកម្លាំងការងារជាច្រើនបានព្យាយាមធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារទាំងនៅក្នុងស្រុក ទាំងនៅក្រៅប្រទេស។ ស្ត្រីពេញវ័យមួយចំនួន បានព្យាយាមស្វែងរកការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសដើម្បីចេញទៅក្រៅប្រទេសតាមគ្រប់រូបភាព ដែលធ្វើឲ្យជនខិលខូច អាចឆ្លៀតឱកាស និងរកគ្រប់វិធីដើម្បីទាញយកផលប្រយោជន៍ពីសភាពការណ៍ តាមរយៈការនាំមនុស្សឆ្លងដែនខុសច្បាប់ ឬការជួញដូរមនុស្សដើម្បីកេងប្រវ័ញ្ចជាដើម ដែលនាំឲ្យប្រជាពលរដ្ឋទទួលរងគ្រោះ ហើយក៏ជាភាពប្រឈម និងបន្ទុកដ៏ធ្ងន់ធ្ងរសម្រាប់រាជរដ្ឋាភិបាលផងដែរ ។

កន្លងមក យើងបានធ្វើកិច្ចការជាច្រើន មានទាំងការអប់រំ បង្ការ ទប់ស្កាត់ ការបង្ក្រាប ការសង្គ្រោះ ការធ្វើចំណាត់ការតាមប្រព័ន្ធតុលាការដើម្បីផ្តន្ទាទោសជនល្មើស និងរកយុត្តិធម៌ជូនជនរងគ្រោះ ការធ្វើមាតុភូមិនិវត្តន៍ ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មជនរងគ្រោះទៅក្នុងគ្រួសារនិងសហគមន៍ជាដើម ។ តែទោះបីជាមានការខិតខំប្រឹងប្រែងពីមន្ត្រីអនុវត្តច្បាប់ ភ្នាក់ងារមានសមត្ថកិច្ច និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិដែលមានការប្តេជ្ញាចិត្តយ៉ាងណាក៏ដោយ ក៏មិនអាចលុបបំបាត់នូវបញ្ហារងគ្រោះទាំងអស់នេះបានដែរ បើគ្មានការចូលរួមពីបងប្អូនប្រជាពលរដ្ឋដែលជាពលករ ពលការិនី និងជាអ្នកដែលកំពុងប្រថុយប្រថាននឹងភាពខុសច្បាប់ទាំងនោះ ។

ជាការពិតណាស់ដែលថា បងប្អូនប្រជាពលរដ្ឋយើងជាច្រើនកំពុងត្រូវការការងារ និងប្រាក់ចំណូលដែលល្អប្រសើរ តែក៏មិនអាចបណ្តែតបណ្តោយឲ្យភាពរងគ្រោះនៅតែកើតមានបន្តទៀតតាមរបៀបដដែលនេះដែរ ។ យើងនឹងបន្តផ្សព្វផ្សាយអប់រំ ឲ្យកាន់តែទូលំទូលាយ បង្កើនកម្រិតវប្បធម៌ សមត្ថភាពជំនាញបច្ចេកទេស និងការអប់រំដល់ពលករឲ្យមានកម្រិតខ្ពស់ជាងមុន ហើយទាមទារឲ្យមានការធានាផ្នែកច្បាប់

ការតាមដានត្រួតពិនិត្យ និងមានកិច្ចសហប្រតិបត្តិការល្អពីគ្រប់ផ្នែក គ្រប់វិស័យ គ្រប់កម្រិតដើម្បីធានាបាននូវសុវត្ថិភាពពលករ និងដើម្បីកសាងបរិស្ថានល្អប្រសើរ សម្រាប់ជាជម្រើសឲ្យប្រជាពលរដ្ឋឲ្យអាចរស់នៅក្នុងស្រុកក៏ល្អប្រសើរ បើចេញទៅក្រៅប្រទេសក៏ត្រូវប្រកបដោយសេចក្តីថ្លៃថ្នូរ និងមានសុវត្ថិភាព ។

ក្នុងនាម**សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងនាមគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមវាយតម្លៃខ្ពស់និងសូមសម្តែងនូវអំណរគុណចំពោះ ឯកឧត្តមលោកជំទាវ ថ្នាក់ដឹកនាំគ្រប់ក្រសួងស្ថាប័ន ជាសមាជិកសមាជិកានៃគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ ជាពិសេស លេខាធិការដ្ឋានថ្នាក់ជាតិ និងរាជធានីខេត្តព្រមទាំងមន្ត្រី អាជ្ញាធរ សមត្ថកិច្ច អង្គការដៃគូ ជាតិ និងអន្តរជាតិទាំងអស់ ដែលនៅតែបន្តការប្តេជ្ញាចិត្តខិតខំប្រឹងប្រែង ចូលរួម គាំទ្រ និងសហការគ្នា ក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងជួយជនរងគ្រោះកម្ពុជា ព្រមទាំងផ្តល់នូវកាលានុវត្តភាពសម្រាប់ការកសាងភាពសុខដុមរមនា ដល់ប្រទេសជាតិគ្រប់កាលៈទេសៈ ដែលនេះពិតជាស្មារតីទទួលខុសត្រូវប្រកបដោយឧត្តមគតិជាតិគួរឲ្យគោរពសរសើរ ។

គឺមានតែការរួមសាមគ្គីគ្នានេះទេ ដែលអាចដោះស្រាយបញ្ហាដែលកំពុងកើតមានក្នុងសង្គមយើងដោយជោគជ័យបាន ។

ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនជនរួមជាតិទាំងអស់ សូមទទួលបានជោគជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ ។

សូមអរគុណ

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ**

ស ខេង

# មាតិកា

ទំព័រ


**អារម្ភកថា**

I- **ស្ថានភាពទូទៅ**............................................ ១-២

II-**លទ្ធផលការងារ ប.ជ.រ.ព.ភ ឆ្នាំ២០១៣**............................................២-២៥

ក-ការរៀបចំច្បាប់-បទដ្ឋាន និងគោលនយោបាយ............................................២-៣

ខ-ការងារដឹកនាំសម្របសម្រួល............................................៣-៩

គ-ការអនុវត្តន៍យុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស............................................១០-២២

១-ការងារបង្ការ-ទប់ស្កាត់............................................១០-១៥

១.១-ការផ្សព្វផ្សាយ អប់រំ បង្ការ............................................១០-១២

១.២-ការអនុវត្តន៍វិធានការទប់ស្កាត់............................................១២-១៥

២-ការងារការពារ-ស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍............................................១៥-១៦

២.១-ការងារការពារ ស្តារនីតិសម្បទាជនរងគ្រោះ............................................១៥

២.២-ការទទួលពលករពីអាជ្ញាធរបរទេស............................................១៥

២.២.១-តាមរយៈអាជ្ញាធរបរទេស............................................១៥-១៦

២.២.២-តាមរយៈក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ.១៦

៣-ការងារអនុវត្តច្បាប់............................................១៦-១៧

៤-ការងារកិច្ចការយុត្តិធម៌............................................១៧-១៨

៥-ការងារសហប្រតិបត្តិការអន្តរជាតិ............................................១៨-២១

៦-ការងារកិច្ចការកុមារ............................................២១-២២

៧-ការងារទេសន្តរប្រវេសន៍............................................២២

ឃ-ការលើកកម្ពស់សមត្ថភាព............................................២២-២៥

១-ការបណ្តុះបណ្តាល............................................២២-២៤

២-សិក្ខាសាលា............................................២៤-២៥

III-**ការសន្និដ្ឋាន វាយតម្លៃលើលទ្ធផលសកម្មភាពឆ្នាំ ២០១៣**............................................២៥-២៧

ក-ចំនុចខ្លាំង............................................២៥-២៦

ខ-ចំណុចសេសសល់ និងភាពប្រឈម............................................២៦

គ-ការសន្និដ្ឋាន វាយតម្លៃ............................................២៦-២៧

IV-**ទិសដៅសម្រាប់អនុវត្តឆ្នាំ២០១៤**............................................២៧-២៩

ក-ការងារច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តិ............................................២៧

ខ-ការងារផែនការ............................................២៧

គ-ការងារអប់រំផ្សព្វផ្សាយ............................................២៨

ឃ-ការងារអភិវឌ្ឍន៍ធនធានមនុស្ស............................................២៨

នៅតាមតំបន់ទេសចរណ៍ជាដើម ទទួលរងគ្រោះដោយការរំលោភបំពានផ្លូវភេទ ពីសំណាក់ភ្ញៀវទេសចរណ៍មួយចំនួន ទាំងជនបរទេស ទាំងជនជាតិកម្ពុជា ។

គឺអាស្រ័យដោយស្ថានភាព និងរូបភាពនៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើផ្លូវភេទ និងកម្លាំងពលកម្ម ដែលបាន និងកំពុងតែបន្តកើតមាន ទាំងនេះហើយ ទើបគណៈកម្មាធិការជាតិ ចាំបាច់ត្រូវបន្តកិច្ចខិតខំប្រឹងប្រែងពង្រឹងកិច្ចសហការបន្ថែមទៀត ដើម្បីសិក្សាស្វែងយល់អំពីភាពប្រឈមដែលប្រទាក់ក្រឡាគ្នាយ៉ាងស្មុគស្មាញ ទាំងកត្តាខាងក្នុង ទាំងកត្តាខាងក្រៅ និងដើម្បីកំណត់រកយុទ្ធសាស្ត្រ និងវិធានការដែលមានប្រសិទ្ធភាព ដែលត្រូវរួមគ្នាដោះស្រាយ ជាលក្ខណៈពហុវិស័យ ។

លើសពីនេះទៅទៀត ផ្អែកលើការវាយតម្លៃការអនុវត្តផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១១-២០១៣ គណៈកម្មាធិការជាតិដឹកនាំ ប ជ.រ.ព.ភ.បានរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិ ជំហានទី២ ឆ្នាំ ២០១៤-២០១៨ និងត្រូវកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ តួនាទីភារកិច្ច និងរបៀបរបបការងារនៃយន្តការគ្រប់ថ្នាក់ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ ។

## II- លទ្ធផលការងារ ប.ជ.រ.ព.ភឆ្នាំ២០១៣

នៅក្នុងឆ្នាំ២០១៣កន្លងទៅនេះ គណៈកម្មាធិការជាតិ និងថ្នាក់ក្រោមជាតិ ប.ជ.រ.ព.ភ បានបន្តយកចិត្តទុកដាក់អនុវត្តអនុវត្តផែនការសកម្មភាព និងទិសដៅភារកិច្ចរបស់ខ្លួន ដោយពង្រឹងកិច្ចសហប្រតិបត្តិការរវាងបណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនិងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិទីភ្នាក់ងារសហប្រជា ជាតិ និងទីភ្នាក់ងារក្រុមហ៊ុនឯកជន និងបានធ្វើឲ្យសម្រេចនូវលទ្ធផលដូចខាងក្រោម ៖

ក- <u>ការរៀបចំច្បាប់-បទដ្ឋាន និងគោលនយោបាយ</u>

បានដាក់ចេញលិខិតបទដ្ឋានចំនួន២៦ និងរៀបចំសេចក្តីព្រាងបទដ្ឋានមួយចំនួន មានជាអាទិ៍៖

- រាជរដ្ឋាភិបាលកម្ពុជាចេញគោលការណ៍ណែនាំលេខ០១ គកន ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរពលករទេសន្តរប្រវេសន៍កម្ពុជា ។
- គណៈកម្មាធិការជាតិ បានជម្រុញឲ្យលេខាធិការដ្ឋានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ អនុក្រឹត្យ និងបទដ្ឋានគតិយុត្តិមួយចំនួនពាក់ព័ន្ធនឹងការរៀបចំកែសម្រួលរចនាសម្ព័ន្ធនៃយន្តការគណៈកម្មាធិការជាតិ អគ្គលេខាធិការដ្ឋាន និងយន្តការថ្នាក់ក្រោមជាតិ ដើម្បីធានាប្រតិបត្តិការក្នុងសកម្មភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព ដែលឯកសារទាំងអស់នេះនឹងត្រូវបានដាក់ចេញក្នុងឆ្នាំ ២០១៤។
- ក្រសួងយុត្តិធម៌ចេញសេចក្តីប្រកាសលេខ ៩៤កយ.ប្រក/១៣ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រុមស្រាវជ្រាវថ្នាក់តំបន់ ពាក់ព័ន្ធទេសចរណ៍ផ្លូវភេទលើកុមារ ។
- ដើម្បីអនុវត្តអនុក្រឹត្យ លេខ១៩០ អនក្រ.បក ស្តីពីការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចេញសេចក្តីប្រកាសចំនួន០៨ ដូចខាងក្រោម ៖
    - ប្រកាសលេខ០៤៥/១៣ ក.ប/ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឲ្យប្រើពាក្យគន្លឹះ
    - ប្រកាសលេខ ០៤៦/១៣ ក.ប/ប្រក ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៣ ស្តីពីដំណើការជ្រើរើស និងការណែនាំ តម្រង់ទិសពលករមុនពេលចេញដំណើរ
    - ប្រកាសលេខ ០៤៧/១៣ ក.ប/ប្រក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីទីភ្នាក់ងារជ្រើសរើសឯកជន

NATIONAL COMMITTEE TO LEAD S.T.S.S. ប.ជ.រ.ព.ភ

- ប្រកាសលេខ២៤៩ ក.ប/ក្របចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីយន្តការទទួលពាក្យបណ្តឹងពលករទេសន្តរប្រវេសន៍
- ប្រកាសលេខ ២៥០ ក.ប/ក្រប ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីអធិការកិច្ចភ្នាក់ងារជ្រើសរើសឯកជន
- ប្រកាសលេខ ២៥១ ក.ប/ប្រក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការលើកសរសើរ និងការដាក់វិន័យទីភ្នាក់ងារជ្រើសរើសឯកជន
- ប្រកាសលេខ ២៥២ ក.ប/ប្រក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីសេវាទីភ្នាក់ងារជ្រើសរើសឯកជននៅកន្លែងធ្វើការ និងការធ្វើមាតុភូមិនិវត្តន៍
- ប្រកាសលេខ ២៥៣ ក.ប/ប្រក ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការដាក់ឲ្យប្រើប្រាស់បទដ្ឋានអប្បបរមាកិច្ចសន្យាសេវាករការងារឲ្យធ្វើនៅបរទេសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

<u>គណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ រាជធានី-ខេត្តចំនួន ១៥៖</u>

បានចេញសេចក្តីសម្រេច បង្កើតសមាសភាពក្រុមការងារទេសន្តរប្រវេសន៍ ដែលមាន៖ ខេត្តបៃលិន ព្រះសីហនុ កែប កំពត កំពង់ស្ពឺបន្ទាយមានជ័យ ស្វាយរៀង កំពង់ធំ ក្រចេះ ឧត្តរមានជ័យកោះកុង សៀមរាប ព្រះវិហារ ខេត្តពោធិ៍សាត់ និងរាជធានីភ្នំពេញ ។

- <u>លេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ ខេត្តក្រចេះ</u>

ចេញសេចក្តីសម្រេចលេខ២៥សសរ.ក្រច ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការប្រគល់ភារកិច្ចបន្ថែមជូន លោក **ជាក់ ម៉េងហ៊ាង** អភិបាលរងខេត្តទទួលការងារ ប.ជ.រ.ព.ភ ជំនួសលោកស្រី **ប៊ិន សុភី** ដែលបច្ចុប្បន្ន កំពុងបំពេញកម្មសិក្សានៅសាលាភូមិន្ទរដ្ឋបាល ។

### ខ- <u>*ការងារដឹកនាំសម្របសម្រួល:*</u>

ក្នុងឆ្នាំ២០១៣កន្លងទៅការងារដឹកនាំ និងសម្របសម្រួលសរុប មានចំនួន**២៤៩**លើក គឺធ្វើដោយ៖

- គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ ចំនួន០៣លើក
- លេខាធិការដ្ឋានជាតិប.ជ.រ.ព.ភ ចំនួន៤៣លើក
- ក្រសួងកិច្ចការនារីចំនួន០៤លើក
- ក្រសួងទេសចរណ៍ចំនួន០១លើក
- ក្រសួងសង្គមកិច្ចចំនួន១១លើក
- ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន០៦លើក
- ក្រុមការងារCOMMITកម្ពុជាចំនួន**០៥**លើក
- ក្រុមការងារបង្ការទប់ស្កាត់ ចំនួន**០១**លើក
- ក្រុមការងារអនុវត្តច្បាប់ចំនួន០៨លើក
- ក្រុមការងារសហប្រតិបត្តិការអន្តរជាតិចំនួន០១លើក
- ក្រុមការងារកិច្ចការយុត្តិធម៌ចំនួន០៥លើក
- ក្រុមការងារទេសន្តរប្រវេសន៍ចំនួន០៥លើក
- ក្រុមការងារSOMTC ចំនួន០១លើក
- លេខាធិការដ្ឋានរាជធានី-ខេត្តចំនួន១៥៤លើក ។

NATIONAL COMMITTEE TO LEAD S.T.S.L.S.

ប្រៀបធៀបទៅនឹងឆ្នាំ ២០១២ គឺកិច្ចប្រជុំសម្របសម្រួលកើនចំនួន៥២លើក ។

<u>តារាងការងារដឹកនាំសម្របសម្រួល</u>

| ស្ថាប័ន សម្របសម្រួល | សកម្មភាព | ស្ថាប័ន និងបុគ្គលពាក់ព័ន្ធ |
|---|---|---|
| គណៈកម្មាធិការជាតិដឹកនាំប.ជ.រ.ព.ភ ចំនួន០៣លើក | - សន្និបាតបូកសរុបការងារប្រចាំឆ្នាំ២០១២<br>- សិក្ខាសាលាថ្នាក់ជាតិស្តីពីការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ ។<br>- ដឹកនាំកិច្ចប្រជុំស្តីពីការរៀបចំព្រះរាជក្រឹត្យដើម្បីបង្កើតគណៈកម្មាធិការជាតិបង្ក្រាបរាល់ទម្រង់នៃការជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ ។ | សមាជិកគណៈកម្មាធិការជាតិ |
| លេខាធិការដ្ឋានជាតិ ប.ជ.រ.ព.ភ ចំនួន៤៣លើក | - ប្រជុំត្រៀមរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពីការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍(០២លើក)។<br>- ប្រជុំពិនិត្យលើរបាយការណ៍បូកសរុបសកម្មភាពនិងលទ្ធផលការងារប.ជ.រ.ព.ភ ឆ្នាំ២០១២ និងទិសដៅឆ្នាំ២០១៣ និងត្រៀមសិក្ខាសាលា(០៣លើក )។<br>- ប្រជុំពិនិត្យ និងផ្តល់អនុសាសន៍លើសេចក្តីព្រាងប្រកាសរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(០១លើក)<br>- ប្រជុំបញ្ហាការងារទេសន្តរប្រវេសន៍ និងការកសាងផែនការសកម្មភាព ចំនួន(០៥លើក)។<br>- ប្រជុំពិនិត្យនិងរៀបចំលើខ្សែវីដេអូខ្លី ស្តីពីការរំលោភបំពានផ្លូវភេទលើកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតទៅលើកុមារ និងឯកសារដើម្បីផ្សព្វផ្សាយបង្ការ-ទប់ស្កាត់លើរថយន្តក្រុង ទីប្រជុំជននិងក្នុងព្រលានយន្តហោះអន្តរជាតិ(ភ្នំពេញសៀមរាប និងព្រះសីហនុ) (០៦លើក)។<br>- ប្រជុំពង្រឹងកិច្ចសហប្រតិបត្តិការរវាងលេខាធិការដ្ឋានជាតិនិងអ្នកពាក់ព័ន្ធក្នុងការងារប្រយុទ្ធប្រឆាំង នឹងអំពើជួញដូរមនុស្សនៅកម្ពុជា(០៣លើក)។<br>- ប្រជុំពិភាក្សា ពិគ្រោះយោបល់អំពីក្របខណ្ឌច្បាប់ពាក់ព័ន្ធនីតិវិធីស្រាវជ្រាវស៊ើបអង្កេតដោយសម្ងាត់(០៤លើក)<br>- ប្រជុំជួបស្ថានទូតអាមេរិក ក្នុងការវាយតម្លៃ និងកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា(០៤លើក) ។ | - សមាជិកលេខាធិការដ្ឋានជាតិ<br>- ក្រុមការងារទាំង៧<br>- ក្រសួងសង្គមកិច្ច<br>- ក្រសួងយុត្តិធម៌<br>- ស្ថានទូតអាមេរិក<br>- FBI និង ICE<br>- អង្គការវីនរ៉ក់<br>- អង្គការដៃគូពាក់ព័ន្ធ៖ARTIP, Afesip,AAPTIP, CambodiaACTs, Worldvision, UNODC,USAID, Child Wise, IJM, Intervita,RANGE, WCC<br>- លេខាធិការដ្ឋានរាជធានីខេត្ត |

| | | |
|---|---|---|
| | - ប្រជុំសម្របសម្រួលកែខ្លឹមសារអនុស្សរណៈ នៃការយោគយល់គ្នារបស់អង្គការការពារកុមារនិងរបស់អង្គការIJM (០២លើក)។<br>- ប្រជុំពិភាក្សាបង្កើតក្រុមការងារបណ្តុះបណ្តាលរបស់ថ្នាក់ជាតិ ចុះបង្រៀន និងពង្រឹងសមត្ថភាពយល់ដឹងតាមបណ្តាលេខាធិការដ្ឋាន រាជធានី-ខេត្ត (០១លើក)។<br>- ប្រជុំពិភាក្សាលើការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ និងតុលាការលើការស៊ើបអង្កេតជាសម្ងាត់ និងកិច្ចសហប្រតិបត្តិការបង្ក្រាបបទល្មើសពាក់ព័ន្ធ នឹងអំពើជួញដូរមនុស្ស (០១លើក)។<br>- ប្រជុំរៀបចំសិក្ខាសាលា ស្តីពីទេសន្តរប្រវេសន៍ការងារនៅខេត្តបន្ទាយមានជ័យ (០២លើក)។<br>- ប្រជុំពិគ្រោះយោបល់អ្នកពាក់ព័ន្ធបង្កើតគោលការណ៍ណែនាំប្រព័ន្ធត្រួតពិនិត្យតាមដាន(០១លើក) ។<br>- ដឹកនាំកិច្ចប្រជុំស្តាប់ក្រុមសិក្សាស្រាវជ្រាវក្នុងការពិនិត្យវាយតម្លៃ លើការអនុវត្តផែនកាសកម្មភាពជាតិប.ជ.រ.ព.ភ ឆ្នាំ២០១១-២០១៣ និងត្រៀមរៀបចំផែនការសកម្មភាពជាតិដើម្បីអនុវត្តបន្តសម្រាប់ឆ្នាំ២០១៤-២០១៨ (០២លើក)។<br>- វគ្គកសាងសមត្ថភាពការងារតាមដានវាយតម្លៃ ជាមួយគម្រោង AAPTIP(០១លើក)។<br>- ដឹកនាំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់(ធ្វើនៅខេត្តព្រះសីហនុ ១២ខេត្តនៅខេត្តបាត់ដំបង ១២ខេត្ត) ដើម្បីវាយតម្លៃផែនការសកម្មភាពជាតិ និងការកសាងផែនការសកម្មភាពជាតិបន្ត (០២លើក )។<br>- ដឹកនាំកិច្ចប្រជុំពិនិត្យរៀបចំឯកសារព្រះរាជក្រឹត្យ អនុក្រឹត្យ ពាក់ព័ន្ធការកែសម្រួលយន្តការជាតិ និងថ្នាក់ក្រោមជាតិ (០២លើក)។<br>- ដឹកនាំក្រុមទេសន្តរប្រវេសន៍ធ្វើទស្សនៈកិច្ចសិក្សានៅក្រុមហ៊ុន(០១លើក)។<br>- ប្រជុំពិភាក្សាជាមួយអង្គការដៃគូ លើកិច្ចសហប្រតិបត្តិការ (០១លើក)។ | |

| | | |
|---|---|---|
| ក្រសួងទេសចរណ៍ ចំនួន០១លើក | - ពិភាក្សាការងារលើកកម្ពស់សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍និងលើកទិសដៅអនុវត្តបន្ត | - ក្រសួងទេសចរណ៍ អង្គការអ៊ិកផាតកម្ពុជា និងអង្គការទស្សនៈពិភពលោក |
| ក្រសួងកិច្ចការនារី ចំនួន០៤លើក | - ប្រជុំពិនិត្យ និងកែសម្រួលសេចក្តីព្រាងឯកសារសម្រាប់បណ្តុះបណ្តាលដល់មន្ត្រីបង្គោលថ្នាក់ក្រោមជាតិស្តីពីយេនឌ័រ និងទេសន្តរប្រវេសន៍ ។<br>- ប្រជុំពិនិត្យសកម្មភាពការងារត្រីមាសទី១ ត្រីមាសទី២ ត្រីមាសទី៣ (ចំនួន០៣លើក) | - សមាជិកក្រសួងកិច្ចការនារី |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទាចំនួន១១លើក | - ចាត់មន្ត្រី ០២រូប ជាគ្រូឧទ្ទេស បណ្តុះបណ្តាល ស្តីពីយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។<br>-ដឹកនាំកិច្ចប្រជុំ ស្តីពីការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនិងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស (០៥លើក)។<br>-ដឹកនាំកិច្ចប្រជុំរៀបចំសេចក្តីព្រាង ប្រកាសស្តីពីបទដ្ឋានអប្បបរមា ថែទាំជនរងគ្រោះ នៅក្នុងមជ្ឈមណ្ឌល ។<br>-កែសម្រួលសេចក្តីព្រាងអនុក្រឹត្យ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះ ស្នាក់នៅក្នុងមជ្ឈមណ្ឌល ។<br>-ប្រជុំរៀបចំឧបករណ៍ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ស្តីពីកិច្ចការពារជនរងគ្រោះ (០៣លើក) | - សមាជិកក្រុមការងារ |
| ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ០៦លើក | - ផ្សព្វផ្សាយខ្លឹមសារនៃអនុសញ្ញាអន្តរជាតិ ស្តីពីការការពារសិទ្ធិពលករទេសន្តរប្រវេសន៍ (ចំនួន០៣លើក)។<br>- ពិភាក្សាការងារអ្នកឯកទេសអង្គការពលកម្មអន្តរជាតិលើការងារទេសន្តរប្រវេសន៍។<br>- ប្រជុំក្រុមការងាររៀបចំសេចក្តីព្រាងលិខិតតូបករណ៍អាស៊ាន ស្តីពីការការពារ និងការលើកកម្ពស់សិទ្ធិពលករ<br>- ប្រជុំរៀបចំគ្រូបណ្តុះបណ្តាលសម្រាប់អប់រំណែនាំតម្រង់ទិសទីភ្នាក់ងារឯកជន។ | - សមាជិកក្រុមការងារ |
| ក្រុមការងារ COMMIT ចំនួន០៥លើក | - ប្រជុំជាមួយមន្ត្រីស្ថានទូតអាមេរិកប្រចាំនៅកម្ពុជា បង្ហាញអំពីលទ្ធផលកិច្ចសហប្រតិបត្តិការ និងលទ្ធផលនៃកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់COMMIT លើកទី៩ នៅទីក្រុងបាងកក ប្រទេសថៃ (០១លើក)។<br>- ប្រជុំផ្លាស់ប្តូរបទពិសោធន៍ និងធ្វើការចែករំលែកព័ត៌មានគ្នា ក្នុងការអនុវត្តការងារ (០៣លើក) ។ | - ក្រសួងពាក់ព័ន្ធ<br>- ក្រុមការងារ COMMIT<br>- ក្រុមការងារបង្ការទប់ស្កាត់ |

NATIONAL COMMITTEE TO LEAD S.T.S.L.S


លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ អគារលេខ២១៦ ជាន់ទី៣ ផ្លូវនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន

| | | |
|---|---|---|
| | - ពិភាក្សាលើការធ្វើវិសោធនកម្មអនុស្សរណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងថៃ ស្តីពីកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងការលុបបំបាត់អំពើជួញដូរមនុស្ស និងផែនការ ឆ្នាំ២០១៣-២០១៥តំណាងប្រតិភូទាំងពីររួមគ្នាចុះហត្ថលេខាលើកំណត់ហេតុកិច្ចប្រជុំ(០១លើក) | - ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ<br>- លេខាធិការដ្ឋានជាតិ ប.ជ.រ.ព.ភ និងUNIAP |
| ក្រុមការងារSOMTCចំនួន០១លើក | - ដាក់ឱ្យប្រើប្រាស់សៀវភៅបណ្តុះបណ្តាល និងការអនុវត្តគម្រោង(CAUPATROL PIU) ក្នុងគោលបំណង ពង្រឹងវិធានការបង្ក្រាបលើការរត់ពន្ធជនទេសន្តរប្រវេសន៍ និងទិសដៅសម្រាប់អនាគត ។ | -សមាជិកគណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ<br>-ក្រុមការងារSOMTC<br>-អង្គការ UNODC, Interpol,<br>-អ្នកពាក់ព័ន្ធ |
| ក្រុមការងារទប់ស្កាត់ចំនួន០១លើក | - ប្រជុំកំណត់ខ្លឹមសារផ្សព្វផ្សាយ ដើម្បីបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។ | - សមាជិកក្រុមការងារបង្ការទប់ស្កាត់ |
| ក្រុមការងារអនុវត្តច្បាប់ចំនួន០៨លើក | - ប្រជុំពិភាក្សា ត្រួតពិនិត្យ និងកែសម្រួលលើសៀវភៅបណ្តុះបណ្តាល អំពីការស៊ើបអង្កេត អំពើធ្វើអាជីវកម្មផ្លូវភេទលើកុមារនិងទេសចរណ៍ផ្លូវភេទលើកុមារសម្រាប់មន្ត្រីនគរបាលជួរមុខ និងមន្ត្រីនគរបាលជំនាញស្រប តាមគម្រោងរបស់តំបន់ របស់អង្គការ UNODC ។<br>- ប្រជុំពិភាក្សាលើការរៀបចំគម្រោងសិក្ខាសាលាថ្នាក់ជាតិ ដកបទពិសោធន៍ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទេសចរណ៍ផ្លូវភេទលើកុមារ ។<br>- ប្រជុំស្តីពីការបង្ហាញលទ្ធផលនៃការស្រាវជ្រាវលើការប្រែប្រួលនៃអាជីវកម្មផ្លូវភេទលើកុមារ នៅក្នុងប្រទេសកម្ពុជា របស់អង្គការ (IJM) ។<br>- ប្រជុំពិនិត្យ លើសេចក្តីព្រាងអនុស្សរណៈរវាងអគ្គស្នងការដ្ឋាននគរបាលជាតិ និងអង្គការវីនរ៉ក់ លើកិច្ចសហប្រតិបត្តិការបណ្តុះបណ្តាល ពង្រឹងសមត្ថភាពមន្ត្រីនគរ បាល ។<br>- ប្រជុំជាមួយប៉ូលីសសហព័ន្ធអាល្លឺម៉ង់ ដើម្បីពិនិត្យកិច្ចសហប្រតិបត្តិការរួមគ្នា ប្រឆាំងឧក្រិដ្ឋកម្ម លើកុមារ ។<br>- ប្រជុំដើម្បីដាក់ឆ្លងឯកសារបណ្តុះបណ្តាលមន្ត្រីនគរបាលជួរមុខ ។<br>- ប្រជុំក្រុមការងារបច្ចេកទេសលើកទី២ ដើម្បីពិនិត្យកែ | - សមាជិកក្រុមការងារអនុវត្តច្បាប់<br>- អគ្គស្នងការដ្ឋាននគរបាលជាតិ<br>- អង្គការ UNODC, IJM,Interpol, វីនរ៉ក់, សម្ព័ន្ធចាប់ដៃ<br>- ប៉ូលីសសហព័ន្ធអាល្លឺម៉ង់ |

| | | |
|---|---|---|
| | សម្រួល និងរៀបចំឯកសារសម្រាប់បណ្តុះបណ្តាលមន្ត្រីនគរបាលជួរមុខ និងមន្ត្រីនគរបាលឯកទេស ។<br>- ប្រជុំជាមួយអង្គការសម្ព័ន្ធចាប់ដៃ និងអ្នកជំនាញដើម្បីពិភាក្សាលើការសុំសហការ អនុវត្តគម្រោង Freedom Registry ក្នុងការចែកចាយព័ត៌មានតាមប្រព័ន្ធ Internet | |
| ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ ចំនួន០១លើក | - ប្រជុំត្រៀមលក្ខណៈ ទៅចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់លើកទី៩នៅទីក្រុងបាងកក ប្រទេសថៃ ។ | -សមាជិកក្រុមការងារសហប្រតិបត្តិការអន្តរជាតិ |
| ក្រុមការងារកិច្ចការយុត្តិធម៌ ចំនួន០៥លើក | - បានចុះទៅខេត្តព្រះសីហនុ កំពង់ឆ្នាំង និងខេត្តបាត់ដំបង ជួបជាមួយស្ថាប័នអនុវត្តច្បាប់ (នគរបាល ព្រះរាជអាជ្ញា និងចៅក្រម) ធ្វើការវិភាគរឿងក្តី ពាក់ព័ន្ធការលក់ដូរមនុស្ស ការរួមភេទជាមួយកុមារនិងករណីនាំចេញដោយមិនស្របច្បាប់ដែលតុលា-ការខេត្ត បានជម្រះហើយ ( ០៣លើក)។<br>- ប្រជុំលើកទី២ពិភាក្សារៀបចំសេចក្តីព្រាងប្រកាសរួមរវាងក្រសួងមហាផ្ទៃ និងក្រសួងទេសចរណ៍ស្តីពីសមត្ថកិច្ចរបស់អធិការកិច្ចទេសចរណ៍និងនគរបាលទេសចរណ៍តាមលក្ខខណ្ឌតម្រូវដោយមាត្រា៦៣នៃច្បាប់ស្តីពីទេសចរណ៍ ។<br>- ប្រជុំពិនិត្យ និងវិភាគអំពីការអនុវត្តជាក់ស្តែងសរុបជារបាយការណ៍ដកពិសោធន៍ដោយប្រៀបធៀបនឹងសូចនាករ នៃប្រព័ន្ធវិភាគរឿងក្តី ។ | - សមាជិកលេខាធិការដ្ឋានប.ជ.រ.ព.ភ<br>- ក្រសួងយុត្តិធម៌<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងទេសចរណ៍<br>- អង្គការUNODC អង្គការ ARTIP និងUNIAP |
| ក្រុមការងារទេសន្តរប្រវេសន៍ ចំនួន០៥លើក | - ប្រជុំរៀបចំសិក្ខាសាលាស្តីពីទេសន្តរប្រវេសន៍នៅខេត្តបន្ទាយមានជ័យ ។<br>- -ប្រជុំរៀបចំសិក្ខាសាលា ស្តីពីគំរូអនុវត្តសម្រាប់ការគ្រប់គ្រងពលករឆ្លងដែននៅខេត្តបន្ទាយមានជ័យ ជាមួយអង្គការ កម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ។<br>- ប្រជុំពិភាក្សាការកសាងផែនការសកម្មភាពជាតិ សម្រាប់ឆ្នាំ២០១៤-២០១៨ និងផែនការសកម្មភាពក្រុមការងារទេសន្តរប្រវេសន៍ (០២ លើក)។<br>- ធ្វើទស្សនៈកិច្ចសិក្សាស្វែងយល់តាមក្រុមហ៊ុន(០១លើក) | - លេខាធិការដ្ឋានជាតិដឹកនាំ ប.ជ.រ.ព.ភ<br>- ក្រុមការងារទេសន្តរប្រវេសន៍ និងតំណាងក្រុមហ៊ុន |
| -លេខាធិការដ្ឋានរាជធានី- | - ពង្រឹងរបៀបរបបការងារ | សមាជិកក្រុមការងារក្នុងលេខាធិការដ្ឋាន នៃ |

| | | |
|---|---|---|
| ខេត្តចំនួន១៩បានដឹកនាំកិច្ចប្រជុំសម្របសម្រួលបានចំនួន១៥៥លើក | - រៀបចំខ្លឹមសារផ្សព្វផ្សាយ បង្ការ-ទប់ស្កាត់ អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ<br>- ជម្រុញកិច្ចសហការគ្នាជាមួយអង្គការដៃគូពិភាក្សាអំពីស្ថានភាពពលករទេសន្តរប្រវេសន៍ ដែលចាប់បញ្ជូនមកវិញនិងការធ្វើចំណាកស្រុកដោយសុវត្ថិភាព<br>- ពង្រឹងក្រុមហ៊ុននិងទីភ្នាក់ងារជ្រើស រើសពលករឱ្យអនុវត្តតាមគោលការណ៍ណែនាំ របស់ក្រសួងការងារ<br>- ផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្នុងទម្រង់ធ្ងន់ធ្ងរ<br>- ពិភាក្សាអំពីកិច្ចសហការលើការងារបង្ក្រាបអំពើជួញដូរមនុស្ស ការជួយសង្គ្រោះ និងកិច្ចគាំពារជនរងគ្រោះ | គណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ និងអង្គការដៃគូ |
| **រាជធានី-ខេត្តដែលធ្វើសកម្មភាពមានដូចខាងក្រោម៖** | | |
| ខេត្តកណ្ដាល | សម្របសម្រួលកិច្ចប្រជុំ ចំនួន២១លើក | សមាជិកក្រុមការងារ |
| ខេត្តកោះកុង | សម្របសម្រួលកិច្ចប្រជុំ ចំនួន១១លើក | សមាជិកក្រុមការងារ |
| ខេត្តបន្ទាយមានជ័យ | សម្របសម្រួលកិច្ចប្រជុំ ចំនួន១០លើក | សមាជិកក្រុមការងារ |
| ខេត្តសៀមរាប | សម្របសម្រួលកិច្ចប្រជុំ ចំនួន១៤លើក | សមាជិកក្រុមការងារ |
| ខេត្តព្រះសីហនុ | សម្របសម្រួលកិច្ចប្រជុំ ចំនួន០៥លើក | សមាជិកក្រុមការងារ |
| ខេត្តស្វាយរៀង | សម្របសម្រួលកិច្ចប្រជុំ ចំនួន១០លើក | សមាជិកក្រុមការងារ |
| ខេត្តកំពង់ស្ពឺ | សម្របសម្រួលកិច្ចប្រជុំ ចំនួន០១លើក | សមាជិកក្រុមការងារ |
| ខេត្តព្រៃវែង | សម្របសម្រួលកិច្ចប្រជុំ ចំនួន១៥លើក | សមាជិកក្រុមការងារ |
| ខេត្តព្រះវិហារ | សម្របសម្រួលកិច្ចប្រជុំ ចំនួន០១លើក | សមាជិកក្រុមការងារ |
| ខេត្តកំពង់ឆ្នាំង | សម្របសម្រួលកិច្ចប្រជុំ ចំនួន០២លើក | សមាជិកក្រុមការងារ |
| ខេត្តក្រចេះ | សម្របសម្រួលកិច្ចប្រជុំ ចំនួន០៣លើក | សមាជិកក្រុមការងារ |
| ខេត្តបាត់ដំបង | សម្របសម្រួលកិច្ចប្រជុំ ចំនួន១៧លើក | សមាជិកក្រុមការងារ |
| ខេត្តកំពត | សម្របសម្រួលកិច្ចប្រជុំ ចំនួន០៤លើក | សមាជិកក្រុមការងារ |
| ខេត្តកែប | សម្របសម្រួលកិច្ចប្រជុំ ចំនួន០១លើក | សមាជិកក្រុមការងារ |
| ខេត្តប៉ៃលិន | សម្របសម្រួលកិច្ចប្រជុំ ចំនួន០៣លើក | សមាជិកក្រុមការងារ |
| ខេត្តកំពង់ចាម | សម្របសម្រួលកិច្ចប្រជុំ ចំនួន១៨លើក | សមាជិកក្រុមការងារ |
| ខេត្តពោធិ៍សាត់ | សម្របសម្រួលកិច្ចប្រជុំ ចំនួន០៣លើក | សមាជិកក្រុមការងារ |
| ខេត្តកំពង់ធំ | សម្របសម្រួលកិច្ចប្រជុំ ចំនួន១៣លើក | សមាជិកក្រុមការងារ |
| ខេត្តឧត្តរមានជ័យ | សម្របសម្រួលកិច្ចប្រជុំ ចំនួន០៣លើក | សមាជិកក្រុមការងារ |
| **សរុប** | **មានចំនួន១៥៥ លើក** | |

NATIONAL COMMITTEE TO LEAD S.T.S.L.S

គ- ការអនុវត្តន៍យុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស:

១- ការងារបង្ការ-ទប់ស្កាត់:

១.១-ការផ្សព្វផ្សាយ អប់រំ បង្ការ៖

ក្នុងឆ្នាំ២០១៣កន្លងទៅនេះការងារផ្សព្វផ្សាយទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដែលក្រសួង ស្ថាប័នពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូជាតិ និងអន្តរជាតិ ធ្វើការផ្សព្វផ្សាយជាសាធារណៈ ឲ្យដល់មន្ត្រីពាក់ព័ន្ធ ជនបង្គោល និងប្រជាពលរដ្ឋ សរុបបានចំនួន **៧៩២,៥៣២**នាក់(ស្រី**៣៥៥,៦១៧**នាក់) ។ លើសពីនេះទៅទៀត លេខាធិការដ្ឋានប.ជ.រ.ព.ភថ្នាក់ជាតិ បានសហការជាមួយអង្គការឆាយវ៉ាយស៍ ដើម្បីជាក់តាំងសារ និងរូបភាពផ្ទាំងប៉ាណូ តាមទីសាធារណៈ ដូចជាសួនច្បារជិតព្រះបរមរាជវាំង សាលារៀន ព្រលានយន្តហោះ ការដាក់បញ្ចាំងវីដេអូអប់រំខ្លីតាមរថយន្តក្រុង និងការចូលរួមជាវាគ្មិន ក្នុងកម្មវិធីផ្សព្វផ្សាយតាមកម្មវិធីវិទ្យុរបស់វិទ្យុសម្លេងស្ត្រីកម្ពុជា វិទ្យុអាស៊ីសេរី វិទ្យុសម្លេងសិទ្ធិមនុស្ស វិទ្យុជាតិ ទូរទស្សន៍ស៊ីអិនស៊ី ទូរទស្សន៍ជាតិកម្ពុជា ជាដើម ។

ប្រៀបធៀបតួលេខនៃការផ្សព្វផ្សាយទៅនឹងឆ្នាំ២០១២ ដែលមានត្រឹមតែចំនួន៥១៦,៣៩៧នាក់ គឺចំនួនអ្នកដែលទទួលបានការអប់រំផ្សព្វផ្សាយ កើនឡើងចំនួន**២៧៦,១៣៥នាក់ស្មើនឹង ៥៣,៤៧%**។

ខ្លឹមសារនៃការផ្សព្វផ្សាយទាំងនោះមានជាអាទិ៍ ៖

- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
- កិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- ឧបាយកលជនល្មើស
- ការធ្វើចំណាកស្រុក ដោយសុវត្ថិភាព
- ភាពគ្រោះថ្នាក់ផ្សេងៗពីការធ្វើទេសន្តរប្រវេសន៍ការងារក្រៅប្រទេសដោយ ប្រថុយប្រថាន
- ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារដើម្បីឲ្យកុមារបានចូលរៀនសូត្រ
- ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
- ទេសចរណ៍ផ្លូវភេទលើកុមារ
- គោលនយោបាយភូមិឃុំមានសុវត្ថិភាព ។

ក្រសួង ស្ថាប័នដែលបានធ្វើសកម្មភាពអប់រំ ផ្សព្វផ្សាយមានជាអាទិ៍៖

- ក្រសួងអប់រំ យុវជន និងកីឡា:
  - បានផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់សមាជិកក្រុមការងារថ្នាក់ រាជធានី-ខេត្ត ក្រុង ស្រុក ខ័ណ្ឌ និងថ្នាក់គ្រឹះស្ថានសិក្សាក្នុង១២ខេត្ត បានចំនួន២២៤នាក់ ។
- ក្រសួងទេសចរណ៍:
  - ផ្សព្វផ្សាយច្បាប់ស្តីពី ទេសចរណ៍ សារាចរណែនាំ និងប្រកាសជូនដល់ផ្នែកឯកជន នៃវិស័យទេសចរណ៍នៅតាមបណ្តារាជធានីខេត្ត សរុបបានចំនួន ៨៩៦នាក់ (ស្រី ៣៧៨នាក់) ។
- ក្រសួងកិច្ចការនារី:
  - ចូលរួមជាវាគ្មិន ក្នុងវេទិកាផ្សព្វផ្សាយជាសាធារណៈ ស្តីពីសុវត្ថិភាពចំណាកស្រុក និងការជួញដូរមនុស្ស ដែលរៀបចំឡើងដោយអង្គការCARAMកម្ពុជានៅក្នុងខេត្តកោះកុង ។

- ធ្វើការផ្សព្វផ្សាយ ស្តីពីសកម្មភាពថ្នាក់ភូមិ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្សនៅ ក្នុងភូមិដល់ប្រជាពលរដ្ឋចំនួន៦០០នាក់ (ស្រី៣១៦នាក់) ក្នុងខេត្តកោះកុង បន្ទាយមានជ័យ កំពង់ចាម ។
- ចូលរួមជាវាគ្មិនក្នុងកម្មវិធីរបស់វិទ្យុ FM 102 ក្រោមប្រធានបទ រូបភាព និងសម្ភារៈអាសអាភាស ។

- <u>ក្រសួងការងារបណ្តុះបណ្តាលនិងវិជ្ជាជីវៈ</u>
  - ចូលរួមជាវាគ្មិន ក្នុងកម្មវិធីរបស់វិទ្យុ FM ១០៦.៥ និង FM ៩៥.៥ ក្រោមប្រធានបទរួមគ្នាបញ្ឈប់ពលកម្មកុមារ នៅខេត្តសៀមរាបចំនួន០៥លើក។
  - ផ្សព្វផ្សាយច្បាប់ស្តីពីការងារ ប្រកាស អនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធពលកម្មកុមារ នៅតាមបណ្តារោងចក្រ សហគ្រាស ចំនួន ១៧០ រោងចក្រ សហគ្រាស ។
  - ចុះត្រួតពិនិត្យ បញ្ហាពលកម្មកុមារ នៅតាមបណ្តារោងចក្រ សហគ្រាស ចំនួន ១៧០ រោងចក្រ សហគ្រាស ។
  - ប្រារព្ធទិវាកុមារអន្តរជាតិ ០១មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា អ្នកចូលរួមចំនួន ៦០០នាក់ ក្នុងនោះមានកុមារចំនួន ៥០០នាក់។
- <u>ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖</u>
  - ផ្សព្វផ្សាយគោលនយោបាយ និងបទដ្ឋានអប្បរមាស្តីពីកិច្ចការពារ សិទ្ធជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ០៥ខេត្ត (ខេត្តកោះកុង តាកែវ ពោធិសាត់ បាត់ដំបង និងស្វាយរៀង) សរុបចំនួនមនុស្ស ១៩០នាក់ (ស្រី៤៩នាក់) ។
- <u>អគ្គស្នងការដ្ឋាននគរបាលជាតិ៖</u>
  - បានចូលរួមផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋបានចំនួន ១៦,៥០១នាក់ (ស្រី ៧,១៨៨នាក់) ។
- <u>អង្គការសកម្មភាពដើម្បីកុមារ(APLE)៖</u>
  - សហការជាមួយអាជ្ញាធរមូលដ្ឋាន នៅលើខេត្តគោលដៅមួយចំនួន(ព្រះសីហនុ, សៀមរាប, បាត់ដំបង, កណ្តាល, កែប, កំពត, កោះកុង និងភ្នំពេញ) បានបើកវគ្គផ្សព្វផ្សាយដល់មន្ត្រីមូលដ្ឋាន អង្គការដៃគូ សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ កុមារក្នុងសហគមន៍ អ្នករត់រ៉ឺម៉កកង់បី អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ និងមន្ត្រីបរទេសមកពីប្រទេស នេប៉ាល់, ហ្វីលីពីន, ឥណ្ឌា, ឥណ្ឌូណេស៊ី, ហុងកុងសរុបបានចំនួន៣.៣៣១នាក់ (ស្រី១.៥១០នាក់) ឱ្យមានការយល់ដឹងលើប្រធានបទពាក់ព័ន្ធការបង្ការ ទប់ស្កាត់ ការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទ ជាពិសេសលើអនីតិជន ។
- <u>គណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ ខេត្ត</u> ៖
  - តាមរយៈយុទ្ធនាការនៃការប្រារព្ធវេទិកាជាតិ១២ធ្នូ និងធ្វើវាគ្មិនផ្សព្វផ្សាយតាមវិទ្យុ០៧លើកសារពាក្យស្លោកមាន១០ផ្ទាំងផ្ទាំងរូបភាព១០០០សន្លឹកអាវយឺត២៥០សៀវភៅ៩០ក្បាល ខិត្តប័ណ្ណមួយចំនួនផ្សព្វផ្សាយតាមគោលដៅ និងមានអ្នកចូលរួមជាក់ស្តែងសរុបបានចំនួន**៧៧១,៤៨៦**នាក់ (ស្រី**៣៤៦,៧៥៤**នាក់)ក្នុងនោះប្រធានលេខាធិការដ្ឋានជាតិបានអញ្ជើញជាអធិបតី នៅក្នុងយុទ្ធនាការ ខេត្តកំពង់ចាម និងខេត្តស្វាយរៀង ៖

| លេខាធិការដ្ឋានរាជធានីខេត្ត | ចំនួនអ្នកចូលរួម(នាក់) | ចំនួនស្ត្រី(នាក់) |
|---|---|---|
| រាជធានីភ្នំពេញ | ៤៧,៨២០ | 0 |
| ខេត្តកណ្តាល | ៩៣,៩៤២ | ៤៨,៥៨៩ |
| ខេត្តស្វាយរៀង | ២៤,៥៩៣ | ១១,៩៦០ |
| ខេត្តសៀមរាប | ៣២,១៤៣ | ១៧,៤៧៦ |
| ខេត្តកំពង់ឆ្នាំង | ៤២,៥២៩ | ៨,៩១៣ |
| ខេត្តព្រះវិហារ | ១៤៥,៥៥៩ | ៧៧,១៨៨ |
| ខេត្តព្រះសីហនុ | ១១,២៣៣ | ៧,៦៨៥ |
| ខេត្តក្រចេះ | ១,៣៨៨ | ៤៥៩ |
| ខេត្តកំពង់ស្ពឺ | ៤៥,៨២៩ | ២៦,៤២៥ |
| ខេត្តបាត់ដំបង | ១៨៤,៣៦៦ | ៧៧,០២០ |
| ខេត្តកំពង់ធំ | ៤,៩៤៥ | ៣,៥១៣ |
| ខេត្តតាកែវ | ៧,៥៦៨ | ៣,៨៤៣ |
| ខេត្តបន្ទាយមានជ័យ | ៨៧១ | ៤៦៨ |
| ខេត្តកំពត | ២៩,២០០ | ១៣,៩២១ |
| ខេត្តកែប | ២៩,៦៦២ | ១២,៥៥៦ |
| ខេត្តព្រៃវែង | ៩,៧២៩ | ៤,៥៩០ |
| ខេត្តកោះកុង | ១,៤១៦ | ៨៦២ |
| ខេត្តពោធិ៍សាត់ | ៥០,៨៦៤ | ២៦,៥៦២ |
| ខេត្តកំពង់ចាម | ៣,៥៤៤ | ២,៧៤០ |
| ខេត្តឧត្តរមានជ័យ | ១,០៩៩ | ៧៤៤ |
| ខេត្តរតនៈគីរី | ២,២៨៣ | ៧៥៣ |
| ខេត្តបៃលិន | ២៣១ | ១២៥ |
| ខេត្តមណ្ឌលគីរី | ៦៧២ | ៣៦២ |
| **សរុប** | **៧៧១,៤៨៦** | **៣៤៦,៧៥៤** |

១.២- ការអនុវត្តវិធានការទប់ស្កាត់

ពិនិត្យជារួម ក្នុងឆ្នាំ២០១៣នេះនៅនេះ សមត្ថកិច្ចទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានរួមសហការជាមួយស្ថាប័នជំនាញ អង្គភាពពាក់ព័ន្ធ អនុវត្តការងារបង្ការទប់ស្កាត់មានលទ្ធផល ដូចខាងក្រោម ៖

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត:

- ល្បាតឃ្លាំមើលគោលដៅសង្ស័យប្រព្រឹត្តបទល្មើសសញ្ជារកម្មចំនួន២៨៤លើក ។
- ណែនាំដល់បណ្តាម្ចាស់អាជីវកម្មពាក់ព័ន្ធមិនឱ្យប្រព្រឹត្តអំពើសញ្ជារកម្មបានចំនួន២៨៥គោលដៅ ។
- តាមដានបច្ចុប្បន្នភាពស្ថិតិ និងគ្រប់គ្រងប្រជាពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកស្វែង រកការងារដោយប្រថុយប្រថាន ។

ដោយប្រៀបធៀបតួលេខនៃចំនួនប្រជាពលរដ្ឋធ្វើចំណាកស្រុក តាមបណ្តាខេត្ត ដែលប្រែប្រួលតាមខែនីមួយៗក្នុងឆ្នាំ២០១៣មានដូចខាងក្រោម៖

**តារាងទិន្នន័យប្រជាជនចំណាកស្រុក ដែលប្រមូលបានដោយនគរបាលនៅទូទាំងប្រទេស គិតតាមខែ**

| ល.រ. | គិតក្នុងខែ | ចំនួនប្រ/រដ្ឋចំណាកស្រុក ប្រែប្រួលតាមខែ នីមួយៗ | ចំនួនស្ត្រី | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | មករា | ១០៣,០៥១នាក់ | ៤២,២៧០នាក់ | |
| ២ | កុម្ភៈ | ១៥៣,៦៤៩នាក់ | ៦៥,៥២៤នាក់ | |
| ៣ | មិនា | ១៩២,៥០៩នាក់ | ៨០,៦៤៨នាក់ | |
| ៤ | មេសា | ២០១,០៦៩នាក់ | ៩៦,៥០៩នាក់ | |
| ៥ | ឧសភា | ២១៩,១៧៥នាក់ | ៨៩,៦៦៣នាក់ | |
| ៦ | មិថុនា | ២៣៦,៥៣២នាក់ | ៩៧,៩៤៨នាក់ | |
| ៧ | កក្កដា | ២៤៣,៨៧៩នាក់ | ១០១,៥២៨នាក់ | មានកំណើន |
| ៨ | សីហា | ២៥៨,១៨៦នាក់ | ១០៧,៣៨២នាក់ | បន្តកើន |
| ៩ | កញ្ញា | ២៧២,៧១៤នាក់ | ១១១,៣៥៧នាក់ | បន្តកើន |
| ១០ | តុលា | ២៧៥,០៤៩នាក់ | ១១៧,៥៣៧នាក់ | បន្តកើន |
| ១១ | វិច្ឆិកា | ៣០០.៤៧៤នាក់ | ១២៤.៧២៩នាក់ | បន្តកើន |
| ១២ | ធ្នូ | ៣២៥,៥២៥នាក់ | ១៣៣.០០៧នាក់ | បន្តកើន |

***សម្គាល់៖*** *ចំនួននេះ មិនបានញែកចំនួនអ្នកដែលត្រឡប់ទៅមកទេ ពោលគឺគ្រាន់តែអាចប៉ាន់ប្រមាណពីទំហំនៃភាពចល័តចំណាកស្រុករបស់ប្រជាពលរដ្ឋតាមខែនីមួយៗប៉ុណ្ណោះ ។*

**<u>ក្រាហ្វិកនៃចំណាកស្រុកតាមខែនីមួយៗ</u>**



- **លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំ ប.ជ.រ.ព.ភ រាជធានី-ខេត្ត ៖**

លេខាធិការដ្ឋានខេត្តចំនួន១២ (បន្ទាយមានជ័យបាត់ដំបងក្រចេះស្ទឹងត្រែងកោះកុងព្រះសីហនុ កំពង់ស្ពឺ ប៉ៃលិន ព្រៃវែង កំពត ខេត្តព្រះវិហារនិងកំពង់ឆ្នាំង) បានអប់រំ និងបង្ការទប់ស្កាត់ **សរុបបានចំនួន ១០,៩៣១នាក់ ស្រីចំនួន៣,៣៤៣នាក់ ។**

បើប្រៀបធៀបទៅនឹងការបង្ការទប់ស្កាត់ក្នុងឆ្នាំ២០១២ ប្រជាពលរដ្ឋ និងពលករទេសន្តរប្រវេសន៍ ដែលឆ្លងដែនខុសច្បាប់ មានការថយចុះចំនួន៤៩,៤១៦នាក់ស្មើនឹង៨១,៨៨ភាគរយ។

**តារាងសកម្មភាពអប់រំបង្ការទប់ស្កាត់**

| ល.រ | លេខាធិការដ្ឋានខេត្ត | សកម្មភាពទប់ស្កាត់ | ចំនួនរួម | ស្រី |
|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ទប់ស្កាត់ និងអប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើចំណាកស្រុកឆ្លងដែនខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ | ៦៥៤៩នាក់ | ២១៣១នាក់ |
| ២ | បាត់ដំបង | ទប់ស្កាត់និងអប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើចំណាកស្រុកដោយខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ | ៣៦៦៦នាក់ | ១១៦២នាក់ |
| ៣ | កោះកុង | ទប់ស្កាត់និងអប់រំប្រជាពលរដ្ឋដែលត្រៀមធ្វើចំណាកស្រុកដោយខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ | ៧១នាក់ | ០៨នាក់ |
| ៤ | ខេត្តព្រះវិហារ | ទប់ស្កាត់ និងអប់រំប្រជាពលរដ្ឋចំណាកស្រុកដែលមានបំណងឆ្លងដែនខុសច្បាប់ ស្វែងរកការងារធ្វើនៅប្រទេសថៃ | ៤៩នាក់ | ០៣នាក់ |
| ៥ | ខេត្តប៉ៃលិន | -ទប់ស្កាត់ និងអប់រំប្រជាពលរដ្ឋចំណាកស្រុកដែលមានបំណងឆ្លងដែនខុសច្បាប់ ស្វែងរក ការងារធ្វើនៅប្រទេសថៃ។ | ៤៨៨នាក់ | ១៨នាក់ |
| ៦ | ស្ទឹងត្រែង | -ទប់ស្កាត់ និងអប់រំប្រជាពលរដ្ឋចំណាកស្រុកដែលមានបំណងឆ្លងដែនខុសច្បាប់ ស្វែងរក ការងារធ្វើនៅប្រទេសថៃ។<br>-អប់រំណែនាំ កន្លែងបញ្ចូលរូបភាពក្នុងទូរស័ព្ទ។ | ១៨នាក់<br>៤០កន្លែង | ០ |
| ៧ | ព្រះសីហនុ | បានកោះអញ្ជើញម្ចាស់ហាងខារ៉ាអូខេ មកធ្វើការផ្សព្វផ្សាយច្បាប់និងណែនាំមិនឲ្យប្រព្រឹត្តអំពើល្មើសផ្ទុយអំពីច្បាប់។ | ៤៧កន្លែង | |
| ៨ | ខេត្តកំពង់ស្ពឺ | បានកោះហៅម្ចាស់ហាងខារ៉ាអូខេ មកធ្វើការផ្សព្វផ្សាយច្បាប់និងណែនាំមិនឲ្យប្រព្រឹត្តអំពើល្មើសផ្ទុយអំពីច្បាប់។ | ៤៤កន្លែង | |
| ៩ | ខេត្តព្រៃវែង | -អប់រំណែនាំដល់ក្រុមហ៊ុនជ្រើសរើសពលករ | ០១ក្រុមហ៊ុន | |

| | | | | |
|---|---|---|---|---|
| | | ដែលកំពុងមានសកម្មភាពក្នុងដែនសមត្ថកិច្ចខេត្ត -អប់រំណែនាំដល់មេខ្យល់ | ០៩នាក់ | 0 |
| ១០ | ខេត្តកំពត | -អប់រំណែនាំដល់អ្នកក្លែងខ្លួនធ្វើសង្ឃចូលទៅដីថៃ | ០៥នាក់ | 0 |
| ១១ | ខេត្តក្រចេះ | -អប់រំណែនាំដល់កន្លែងថត និងជួលកាសែតវីដេអូ | ០៥កន្លែង | |
| ១២ | ខេត្តកំពង់ឆ្នាំង | -ទប់ស្កាត់ និងអប់រំប្រជាពលរដ្ឋចំណាកស្រុកដែលមានបំណងឆ្លងដែនខុសច្បាប់ ស្វែងរក ការងារធ្វើនៅប្រទេសថៃ។ | ៧៦នាក់ | ២១នាក់ |

២- ការងារការពារ-ស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍:

២.១-ការងារការពារ-ស្តារនីតិសម្បទាជនរងគ្រោះ

ក្នុងឆ្នាំ២០១៣កន្លងទៅនេះមណ្ឌលសំចតខេត្តបន្ទាយមានជ័យ បានដកហូតកុមារ ស្ត្រី និងបុរសរងគ្រោះ និងងាយរងគ្រោះក្រោយពីការកំណត់អត្តសញ្ញាណក្នុងចំណោមទេសន្តរប្រវេសន៍ការងារ ដែលអាជ្ញាធរថៃ បញ្ជូនមកវិញ សរុបបានចំនួន២១២នាក់ ក្នុងនេះបុរស៤៦នាក់ ស្ត្រី២៣នាក់ កុមារ១៤៣នាក់ (កុមារី៦៤នាក់)។ជនរងគ្រោះនិងងាយរងគ្រោះទាំងអស់ត្រូវបានប្រគល់ឲ្យអង្គការដៃគូនិងកំពុងស្វែងរក ធ្វើការប៉ាន់ប្រមាណ ក្នុងការធ្វើសមាហរណកម្មទៅគ្រួសារវិញ ។

- សមត្ថកិច្ចនគរបាលបានសង្គ្រោះជនរងគ្រោះ ហើយប្រគល់ឲ្យមន្ទីរសង្គមកិច្ច បានចំនួន១៥១នាក់ ដើម្បីធ្វើការអប់រំណែនាំ និងស្តារនីតិសម្បទា ។
- ក្រសួងសង្គមកិច្ច បានទទួលជនរងគ្រោះរកស៊ីផ្លូវភេទ សរុបចំនួន ៣១នាក់ ពីខណ្ឌដូនពេញ ក្រុងភ្នំពេញ ០៥នាក់ ពីខេត្តកំពត ០៤នាក់ ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ២០នាក់ (ជនជាតិ វៀតណាម) ពីអង្គការ ចំនួន០២នាក់ ធ្វើការអប់រំ និងបញ្ជូនទៅអង្គការដៃគូដើម្បីស្តារនីតិសម្បទា។
- មន្ទីរសង្គមកិច្ច រាជធានីភ្នំពេញ បានទទួលជនរងគ្រោះ ដោយអំពើជួញដូរសរុបចំនួន ២៧៩នាក់ ស្រី ១៣៤នាក់ ធ្វើការអប់រំណែនាំ និងបញ្ជូនទៅអង្គការដៃគូទទួលសេវាំគាំទ្រ ។

២.២-ការទទួលពលករពីអាជ្ញាធរបរទេស:

២.២.១- តាមរយៈអាជ្ញាធរបរទេស:

ក្នុងឆ្នាំ២០១៣កន្លងទៅនេះការទទួលពលករទេសន្តរប្រវេសន៍ពីអាជ្ញាធរបរទេសមានចំនួន៨០,៩៧៣នាក់ (ស្រី២៤,៥៩៤នាក់) ក្នុងនោះមានកុមារចំនួន៦,៣៤៦នាក់ (កុមារីចំនួន២,២៩៦នាក់)។ ក្នុងចំនួននេះ ពលករត្រូវបានបញ្ជូនមកតាមច្រកទ្វារអន្តរជាតិ និងច្រកទ្វារតំបន់ នៃខេត្តជាប់ព្រំដែនចំនួន០៦គឺច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញច្រកទ្វារអន្តរជាតិប៉ោយប៉ែតខេត្តបន្ទាយមានជ័យច្រកទ្វារអន្តរជាតិដូង ច្រកភ្នំដី ច្រកអូរវ៉ដួលនៃខេត្តបាត់ដំបង ច្រកទ្វារអន្តរជាតិចាំយាមខេត្តកោះកុង ច្រកអន្តរជាតិបាវិតនិងច្រកបុសមននៃខេត្តស្វាយរៀង និងច្រកក្នុងខេត្តព្រះវិហារដោយៈ

+អាជ្ញាធរប្រទេសថៃ សរុបចំនួន៨០,៦១០នាក់ ស្រីចំនួន២៤,៤៤៤នាក់
កុមារចំនួន៦,១៦៦នាក់ កុមារីចំនួន២,២២៨នាក់ ។

+អាជ្ញាធរប្រទេសវៀតណាម សរុបចំនួន២៧២នាក់ ស្រីចំនួន១៤៩នាក់
កុមារចំនួន១៨០នាក់ កុមារីចំនួនកុមារី៦៨នាក់។
+អាជ្ញាធរប្រទេសឡាវ សរុបចំនួន០៣នាក់ ស្រីចំនួន០១នាក់។

__តារាងច្រកទទួលពលករ:__

| ច្រកទ្វារ | ចំនួន(នាក់) | ស្រី(នាក់) | កុមារ(នាក់) | កុមារី(នាក់) |
|---|---|---|---|---|
| អន្តរជាតិភ្នំពេញ(រាជធានីភ្នំពេញ) | ៨៨ | | | |
| អន្តរជាតិប៉ោយប៉ែត (បន្ទាយមានជ័យ) | ៦០,៣៦២ | ១៨,៦៣៥ | ៤,៨៩៨ | ១,៧៧២ |
| អន្តរជាតិដូង ភ្នំដី(គីឡូម៉ែត្រ១៣), អូររំដួល(បាត់ដំបង) | ២០,១៨៣ | ៥,៨០៥ | ១,២៦៨ | ៤៥៦ |
| អន្តរជាតិចាំយាម (កោះកុង) | ៩ | ២ | | |
| អន្តរជាតិបាវិត, បុសមន (ស្វាយរៀង) | ២៧២ | ១៤៩ | ១៨០ | ៦៨ |
| ខេត្តព្រះវិហារ (ពីអាជ្ញាធរថៃ) | ៥៦ | ០២ | | |
| (ពីអាជ្ញាធរឡាវ) | ០៣ | ០១ | | |
| **សរុប** | **៨០,៩៧៣** | **២៤,៥៩៤** | **៦,៣៤៦** | **២,២៩៦** |

ក្នុងចំនួនពលករទេសន្តរប្រវេសន៍ខាងលើ មានមនុស្សចំនួន២,៩៨១នាក់ ត្រូវបានអាជ្ញាធរថៃឃាត់ខ្លួនលើស ពីរយៈពេល០១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ ។ សមត្ថកិច្ចក៏បានធ្វើការសម្ភាសន៍ពលករបានមួយចំនួន ហើយក្តាប់បានអត្តសញ្ញាណជនដែលសង្ស័យថាជាមេខ្យល់ចំនួន០៣នាក់ (ស្រី០១នាក់) ដើម្បីជាមូលដ្ឋានស្វែងរក និងអនុវត្តនីតិវិធីជំនាញ ។ ចំពោះទេសន្តរប្រវេសន៍ទាំងនោះត្រូវបានអប់រំណែនាំឲ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ និងឲ្យមានការប្រុងប្រយ័ត្នចំពោះល្បិចកលជនខិលខូច ។

២.២.២-__តាមរយៈក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ:__

○ អគ្គស្នងការដ្ឋាននគរបាលជាតិ បានទទួលពលករតាមរយៈក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ សហការជាមួយអង្គការដៃគូ បញ្ជូនមកតាមច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ សរុបមានចំនួន ៨៨នាក់ ដូចមានខាងក្រោម៖

-ពីប្រទេសម៉ាឡេស៊ី ចំនួន៣០នាក់
-ពីប្រទេសឥណ្ឌូនេស៊ី ចំនួន៣៦នាក់
-ពីប្រទេសម៉ូរីទីស ចំនួន២២នាក់

ក្នុងចំណោមពលករដែលរាជរដ្ឋាភិបាល សហការជាមួយអង្គការដៃគូពាក់ព័ន្ធបានជួយអន្តរាគមន៍ និងសង្គ្រោះបានពីប្រទេសខាងលើ សមត្ថកិច្ចជំនាញនៃអគ្គស្នងការដ្ឋាននគរបាលជាតិបានសម្ភាសន៍ដើម្បីកំណត់រកអត្តសញ្ញាណជនរងគ្រោះពិតប្រាកដ និងធ្វើសមាហរណកម្មទៅគ្រួសារវិញ។ ក្នុងនោះដែរ សមត្ថកិច្ចយើងបានកំណត់រកឃើញមុខសញ្ញាជនដែលសង្ស័យថាជាមេខ្យល់ក្នុងករណីពាក់ព័ន្ធការជួញដូរមនុស្ស និងកេងប្រវ័ញ្ចមានចំនួន១១នាក់ (ស្រី០៤នាក់) កំពុងកសាងសំណុំរឿងអនុវត្តតាមនីតិវិធីជំនាញ។

៣- __ការងារអនុវត្តន៍ច្បាប់៖__

ក្នុងឆ្នាំ២០១៣កន្លងទៅនេះការបង្ក្រាបបទល្មើសដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបើប្រៀបធៀបទៅនឹងឆ្នាំ២០១២ មានចំនួន៩៩លើ១៣៣ករណី គឺមានការថយចុះចំនួន៣៤ករណី ចាប់ខ្លួនជនសង្ស័យចំនួន១២៥ លើ១៦៥នាក់ គឺមានការថយចុះចំនួន៤០នាក់ ក្នុងនោះមានជនបរទេសចំនួន១៨នាក់(សញ្ជាតិចិន០៤នាក់ ហូឡង់០២នាក់អាល្លឺម៉ង់០២នាក់ កាណាដា០១នាក់ តៃវ៉ាន់០១នាក់អាមេរិក០២នាក់ អូស្ត្រាលី០១នាក់ បារាំង០១នាក់ស្វីស០១នាក់វៀតណាម០១នាក់ និងអង់គ្លេស០២នាក់) ។ក្នុងប្រតិបត្តិការបង្ក្រាបករណីខាងលើ សមត្ថកិច្ច**សង្គ្រោះជនរងគ្រោះបានចំនួន៣១១នាក់** (មានអាយុក្រោម១៥ឆ្នាំចំនួន៧៦នាក់ អាយុ១៥-១៧ឆ្នាំចំនួន៤៩នាក់ និងអាយុ១៨ឆ្នាំឡើងចំនួន១៨៦នាក់) ជនរងគ្រោះទាំងអស់បានប្រគល់ឱ្យមន្ទីរសង្គមកិច្ចចំនួន១៥១នាក់ អង្គការមិនមែនរដ្ឋាភិបាលចំនួន០១នាក់ និងចំនួន១៥៩នាក់ទៀតប្រគល់ជូនក្រុមគ្រួសារវិញ។

- *ក្នុងចំនួន៩៩ករណីជនសង្ស័យ១២៥នាក់(ស្រី៣៧នាក់) ដែលសមត្ថកិច្ចយើងបង្ក្រាប មាន:*

១-អំពើជួញដូរមនុស្សចំនួន**៣៤ករណី** ជនជាប់សង្ស័យចំនួន៤៧នាក់(ស្រី១៩នាក់) ជនរងគ្រោះចំនួនជនរងគ្រោះ៨៨នាក់ ។

២-អំពើធ្វើអាជីវកម្មផ្លូវភេទចំនួន**៦៥ករណី** ជនជាប់សង្ស័យចំនួន៧៨នាក់(ស្រី២០នាក់) ជនរងគ្រោះចំនួនជនរងគ្រោះ២២៣នាក់ ។

តារាងលទ្ធផលកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើស និងសង្គ្រោះជនរងគ្រោះ

| បទល្មើស | ចំនួនករណី | ចំនួនជនសង្ស័យ | ចំនួនជនរងគ្រោះ | | | បញ្ជូនជនរងគ្រោះ | | |
|---|---|---|---|---|---|---|---|---|
| | | | ក្រោម១៥ឆ្នាំ | ១៥-១៧ឆ្នាំ | ១៨ឆ្នាំឡើង | មន្ទីរសង្គមកិច្ច | អង្គការ | គ្រួសារ |
| ជួញដូរមនុស្ស | ៣៤ | ៤៧ | ១៣ | ១៣ | ៦២ | ១៣ | ០១ | ៧៤ |
| អាជីវកម្មភេទ | ៦៥ | ៧៨ | ៤០ | ៤៧ | ១១៣ | ១៣៨ | | ៨៥ |
| សរុប | ៩៩ | ១២៥ | ៣១១ | | | ៣១១ | | |

## ៤- ការងារកិច្ចការយុត្តិធម៌:

នៅក្នុងឆ្នាំ២០១៣កន្លងទៅនេះតាមទិន្នន័យដែលទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌(ក្រសួងយុត្តិធម៌) ដែលបានដកស្រង់ពីតុលាការ និងអយ្យការ នៃសាលាដំបូងរាជធានី-ខេត្តទាំងអស់ បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសជួញដូរមនុស្ស ក្រោមច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ គិតពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣ ដល់ ថ្ងៃទី៣១ខែ១២ ឆ្នាំ២០១៣ ទិន្នន័យដើមមានដូចខាងក្រោម៖

<u>ចំណាត់ការរបស់អយ្យការ រាជធានី-ខេត្ត:</u>

សរុបមានចំនួន **២០៩សំណុំរឿង** ចាត់ការរួចមានចំនួន**១១៦សំណុំរឿង** នៅសល់ចំនួន **៩៣សំណុំរឿង** ដូចមានតារាងខាងក្រោម:

| ចំនួនសំណុំរឿង | ចំណាត់ការរួច | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | | | សំណុំរឿងសេសសល់ |
|---|---|---|---|---|---|---|---|---|---|---|
| | | អនីតិជន | នីតិជន | សរុប | ស្រី | អនីតិជន | នីតិជន | សរុប | ស្រី | |
| ២០៩ | ១១៦ | ៧៩ | ១១៧ | ២២៦ | ១៦៥ | ១៩ | ២១១ | ២៦៦ | ៣១ | ៩៣ |

<u>ចំណាត់ការរបស់ចៅក្រមស៊ើបសួរ រាជធានី-ខេត្តៈ</u>

សរុបមានចំនួន **១៣៧សំណុំរឿង** ចាត់ការរួចមានចំនួន **៥២សំណុំរឿង** នៅសល់ចំនួន **៨៥សំណុំរឿង** ដូចមានតារាងខាងក្រោមៈ

| ចំនួនសំណុំរឿង | ចំណាត់ការរួច | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | | | សំណុំរឿងនៅសល់ | ចំណាត់ការ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | អនីតិជន | នីតិជន | សរុប | ស្រី | អនីតិជន | នីតិជន | សរុប | ស្រី | | ឃុំខ្លួន | ឱ្យនៅក្រៅឃុំ | ជាប់ចោទ | លើកលែងចោទ |
| ១៣៧ | ៥២ | ៥៥ | ១០៤ | ១៨៧ | ១៥៥ | ០៣ | ១៧០ | ១៨៤ | ៤៣ | ៨៥ | ៨២ | ៥៧ | ១៧៥ | ០៩ |

<u>ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ រាជធានី-ខេត្តៈ</u>

សរុបមានចំនួន **១៤០សំណុំរឿង** ចាត់ការរួចមានចំនួន**១០៨សំណុំរឿង** នៅសល់មានចំនួន**៣២សំណុំរឿង** ដូចមានតារាងខាងក្រោមៈ

| ចំនួនសំណុំរឿង | ចំណាត់ការរួច | ចំនួនជនរងគ្រោះ | | | | ចំនួនជនជាប់ចោទ | | | | សំណុំរឿងនៅសល់ | ចំណាត់ការ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | អនីតិជន | នីតិជន | សរុប | ស្រី | អនីតិជន | នីតិជន | សរុប | ស្រី | | ឃុំខ្លួន | ឱ្យនៅក្រៅឃុំ | ផ្តន្ទាទោស | រួចពីបទចោទ |
| ១៤០ | ១០៨ | ៤៨ | ៩៨ | ១៨៥ | ១៦១ | ០៥ | ១៧៤ | ១៩៦ | ៤៨ | ៣២ | ១០៩ | ៥៤ | ១៣២ | ១១ |

ក្នុងការផ្តន្ទាទោសជនល្មើស ចំនួន១៣២នាក់ខាងលើ ការសម្រេចឲ្យជាប់ព័ន្ធនាគារមាន(ក្រោមនិងស្មើ ០៥ឆ្នាំមានចំនួន១១០នាក់ ពី០៥ឆ្នាំដល់១៥ឆ្នាំមានចំនួន២១នាក់លើ១៥ឆ្នាំដល់៣០ឆ្នាំមានចំនួន០១នាក់)។

**៤- <u>ការងារសហប្រតិបត្តិការអន្តរជាតិ</u>**

ក្នុងឆ្នាំ២០១៣ កន្លងទៅនេះ យើងបានទៅចូលរួមកិច្ចប្រជុំ និងបំពេញកិច្ចសហប្រតិបត្តិការលើការងារផ្សេងៗតាមការអញ្ជើញនៃបណ្តាប្រទេសមួយចំនួន សរុប៣២លើក ក្នុងនោះមានៈ

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប.ជ.រ.ព.ភចំនួន ០៤លើក ក្រុមការងារCOMMITកម្ពុជាចំនួន០២លើកក្រសួងយុត្តិធម៌ចំនួន០១លើក ក្រសួងកិច្ចការនារី០៣លើក ក្រសួងសង្គមកិច្ចចំនួន០៤លើក ក្រសួងការងារបណ្តុះបណ្តាលនិងវិជ្ជាជីវៈ០២លើក អគ្គស្នងការដ្ឋាននគរបាលជាតិចំនួន០៩លើក ខេត្តស្វាយរៀង០២លើក ខេត្តព្រៃវែងចំនួន០១លើក ខេត្តកណ្តាលចំនួន០១លើក ខេត្តស្ទឹងត្រែងចំនួន០១លើក និងខេត្តកោះកុង០២លើក ។

**តារាងសកម្មភាពមានដូចខាងក្រោម ៖**

| ក្រសួង-ស្ថាប័ន | សកម្មភាពសហប្រតិបត្តិការ | ទីកន្លែង |
|---|---|---|
| លេខាធិការដ្ឋាននៃ គ.ជ/ប.ជ.រ.ព.ភ៖ ចំនួន០៤លើក | - បានដឹកនាំប្រតិភូធ្វើទស្សនកិច្ចសិក្សានៅប្រទេសម៉ាឡេស៊ី អំពីការបញ្ជូនពលករទេសន្តរប្រវេសន៍?<br>- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងស្ត្រី និងលទ្ធ | ប្រទេសម៉ាឡេស៊ី<br><br>ប្រទេសស្វីស |

| | | |
|---|---|---|
| | ផលនៃការប្រឆាំងការជួញដូរមនុស្ស នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ។<br>- ចូលរួមសិក្ខាសាលាថ្នាក់តំបន់ ស្តីពីការប្រឆាំងអំពើជួញដូរមនុស្សនិងការជួយជនរងគ្រោះ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន<br>- ចូលរួមសិក្ខាសាលាថ្នាក់តំបន់ ជាមួយប្រទេសមហាអនុតំបន់មេគង្គ និងប្រទេសហ្វីលីពីន ស្តីពីការផ្លាស់ប្តូរបទពិសោធន៍ក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សនៅទីក្រុងបាងកក ប្រទេសថៃ ។ | ប្រទេសជប៉ុន<br><br>ប្រទេសហ្វីលីពីន |
| -ក្រុមការងារ COMMIT កម្ពុជា និងលេខាធិការដ្ឋាន គ.ជ/ប.ជ.រ.ព.ភ (ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ)<br>ចំនួន០២លើក | - ដឹកនាំគណៈប្រតិភូកម្ពុជា ទៅចូលរួមក្នុងកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់COMMIT លើកទី៩គោលបំណងធ្វើបច្ចុប្បន្នភាពផ្លាស់ប្តូរបទពិសោធន៍ ភាពជឿនលឿននៃប្រព័ន្ធយុត្តិធម៌ និងកិច្ចសហប្រតិបត្តិការរវាងប្រទេសក្នុងតំបន់(ក្នុងផ្លូវការនិងក្រៅផ្លូវការ)លើកជាអនុសាសន៍ រួមគ្នាក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្សនៅក្នុងប្រទេសមហាអនុតំបន់មេគង្គ (០១លើក)។<br>- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ រៀបចំទស្សនវិស័យ យុទ្ធសាស្ត្រ នៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរួមគ្នាក្រោយឆ្នាំ២០១៣ (០១លើក)<br>- ប្រជុំក្រុមការងារCOMMITថ្នាក់តំបន់រវាងប្រទេសកម្ពុជា ចិន ថៃ ឡាវ មីយ៉ាន់ម៉ា វៀតណាម និងតំណាងអង្គការUNIAP, UNDPប្រចាំប្រទេស(០១លើក)។ | ទីក្រុងបាងកក ប្រទេសថៃ<br><br>ប្រទេកម្ពុជា |
| -ក្រសួងកិច្ចការនារី<br>ចំនួន០៣លើក | ចូលរួមប្រជុំថ្នាក់តំបន់ ផ្លាស់ប្តូរបទពិសោធន៍ក្នុងការធានាប្រព័ន្ធការពារសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងតំបន់។<br>ចូលរួមប្រជុំថ្នាក់តំបន់វេទិកាយុវជនមេគង្គ។<br>ចូលរួមសន្និសីទអន្តរជាតិ ស្តីពីការងារទប់ស្កាត់ និងយុទ្ធសាស្ត្រលប់បំបាត់ការជួញដូរមនុស្សតំបន់អាស៊ីអាគ្នេយ៍។ | នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី<br>នៅប្រទេសថៃ<br>នៅសាធារណៈកូរ៉េ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>ចំនួន០៤លើក | - ចូលរួមប្រជុំថ្នាក់តំបន់ ស្តីពីការផ្លាស់ប្តូរបទពិសោធន៍ក្នុងការធានា នូវការទទួលបានប្រព័ន្ធការពារសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងតំបន់។<br>- ចូលរួមប្រជុំខមមីតលើកទី៩ (SOM9)នៅប្រទេសថៃ។<br>- ចូលរួមប្រជុំថ្នាក់តំបន់មេគង្គលើកទី៤ ស្តីពីយុទ្ធសាស្ត្រ និងការផ្លាស់ប្តូរបទពិសោធន៍ នៅប្រទេសថៃ។<br>- សហការជាមួយអង្គការទស្សនៈពិភពលោកទំនាក់ទំនងជាមួយស្ថានទូតវៀតណាម ធ្វើលិខិតឱ្យកុមារីជនជាតិវៀតណាមធ្វើមាតុភូមិនិវត្តន៍ទៅប្រទេសវិញចំនួន ០៤នាក់។ | ទីក្រុងហ្សាការតា ប្រទេសឥណ្ឌូណេស៊ី<br><br>ប្រទេសថៃ |

| | | |
|---|---|---|
| ក្រសួងការងារបណ្ដុះបណ្ដាល និងវិជ្ជាជីវៈ០២លើក | - រៀបឯកសារនីតិវិធី ប្តឹងតវ៉ាទៅតុលាការម៉ាឡេស៊ី ជូនពលករ<br>- អន្តរាគមន៍ទៅស្ថានទូតនៅប្រទេសថៃ ជួយដល់ពលករ | ប្រទេស ម៉ាឡេស៊ី<br>ប្រទេសថៃ |
| -ក្រសួងយុត្តិធម៌<br>ចំនួន០១លើក | - សហការជាមួយអង្គការUNODC តាមរយៈគម្រោង ស្តីពីកុមារភាពគាំទ្រដោយ AusAID រៀបចំកិច្ចប្រជុំថ្នាក់តំបន់ ស្តីពី "បង្កើតក្រុមការងារស្រាវជ្រាវច្បាប់ថ្នាក់តំបន់" ដែលមានប្រទេសចូលរួម(កម្ពុជា ថៃ ឡាវវៀតណាម) ផ្តោតទៅលើកិច្ចសហប្រតិបត្តិការច្បាប់ព្រហ្មទណ្ឌក្របខណ្ឌច្បាប់ ដើម្បីរួមគ្នាដោះស្រាយក្នុងការប្រយុទ្ធប្រឆាំងទេសចរណ៍ផ្លូវភេទលើកកុមារ (០១លើក)។ | ខេត្តសៀមរាប<br>ប្រទេសកម្ពុជា |
| អគ្គស្នងការដ្ឋាននគរបាលជាតិ<br>ចំនួន០៩លើក | - បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនចំនួន ១៣រូប ទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាកតំបន់០១លើក (UNODC) និងចូលរួម០៣លើកនៅប្រទេសថៃស្តីពីការជួញដូរមនុស្ស ការស៊ើបអង្កេតការ កេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងឧក្រិដ្ឋកម្មអន្តរជាតិ នៅសាធារណៈរដ្ឋកូរ៉េ ០១លើក ។<br>- ស្តីពីការស៊ើបអង្កេត និងវិភាគសកម្មភាពបទល្មើសឧក្រិដ្ឋតាមប្រព័ន្ធកុំព្យូទ័រ (CMIS) នៅទីក្រុងបាងកក ប្រទេសថៃ ០១លើក។<br>- ប្រជុំក្រុមការងារអាស៊ីអាគ្នេយ៍ នៃក្រុមការងារ ជំនាញ INTERPOL ស្តីពីបទល្មើសប្រឆាំងកុមារ ។<br>- កម្មវិធីបង្កើនសន្តិសុខអត្តសញ្ញាណពលរដ្ឋ និងការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅសាធារណរដ្ឋកូរ៉េ ០១ លើក។<br>- សិក្ខាសាលា ស្តីពីជួញដូរផ្លូវភេទលើកុមារក្នុងការធ្វើដំណើរ និងទេសចរណ៍ នៅប្រទេសឡាវ ០១លើក។ | ប្រទេសថៃ<br>សាធារណៈរដ្ឋកូរ៉េ<br><br>ប្រទេសថៃ<br><br>សាធារណៈរដ្ឋកូរ៉េ<br><br>ប្រទេសឡាវ |
| ខេត្តស្វាយរៀង<br>ចំនួន០២លើក | - រៀបចំកិច្ចប្រជុំទ្វេភាគីកម្ពុជា និងវៀតណាមស្តីពីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងការកេងប្រវ័ញ្ចកំលាំងពលកម្ម(០១លើក)។<br>- និងចាត់មន្ត្រីចំនួន០៦រូប ចូលរួមវគ្គបណ្តុះបណ្តាល ជាមួយភាគីវៀតណាម<br>ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ក្នុងកិច្ចសហប្រតិបត្តិការឆ្លងដែន(០១លើក) | ប្រទេសវៀតណាម |
| ខេត្តកណ្តាល<br>ចំនួន០១លើក | - ប្រជុំជាមួយអាជ្ញាធរខេត្តអានភូ ប្រទេសវៀតណាម ក្នុងការបូកសរុបការងារប្រចាំឆ្នាំ២០១២ លើការងារប្រយុទ្ធប្រឆាំង | ប្រទេសវៀតណាម |

| | | |
|---|---|---|
| | នឹងអំពើជួញដូរមនុស្ស ។ | |
| ខេត្តព្រៃវែង<br>ចំនួន០១លើក | - សហការផ្សព្វផ្សាយជាមួយភាគីវៀតណាមក្នុងការបង្ការទប់ស្កាត់បទល្មើសឆ្លងដែនពិសេសការជួញដូរមនុស្ស | |
| ខេត្តស្ទឹងត្រែង<br>ចំនួន០១លើក | - សហការជាមួយអង្គការ IOM បើកសិក្ខាសាលា០១វគ្គ ជាមួយភាគីវៀតណាម ឡាវ និងកម្ពុជា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរួមគ្នា សិក្ខាកាមដែលចូលរួមពីប្រទេសទាំងបីមានចំនួន២០ នាក់ (ស្រី០១នាក់) ។ | ខេត្តស្ទឹងត្រែង |
| ខេត្តកោះកុង<br>ចំនួន០២លើក | - បានចូលរួមប្រជុំ គណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគកម្ពុជា-ថៃលើកទី១៤ នៅខេត្តច័ន្ទបូរី ស្តីពីកិច្ចសហការការពារ ទប់ស្កាត់ប្រជាពលរដ្ឋធ្វើចំណាកស្រុក ។<br>- បានចូលរួមធ្វើទស្សនកិច្ចសិក្សាជាមួយអាជ្ញាធរខេត្តត្រាត ដើម្បីពិភាក្សា លើបញ្ហាពលករខ្មែរនៅលើទូកនេសាទ និងបញ្ហាស្ត្រីខ្មែរដែលទៅទៅធ្វើពេស្យាចារនៅតំបន់ ក្លងស៊ុន ។ | ប្រទេសថៃ<br><br><br>ប្រទេសថៃ |

៦- <u>ការងារកិច្ចការកុមារ</u>

ក្នុងឆ្នាំ២០១៣កន្លងទៅនេះ ក្នុងកិច្ចការពារកុមារ បានធ្វើកិច្ចសហប្រតិបត្តិការលើការងារអាទិភាព មួយចំនួនឆ្លើយតបទៅនឹងអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារដែលមានលទ្ធផល សកម្មភាពដូចខាងក្រោម ៖

- **ក្រុមការងារកិច្ចការកុមារ** រៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ចុះបំប៉នសមត្ថភាពមន្ត្រីជំនាញ ស្តីពី «ច្បាប់ជាតិ និងច្បាប់អន្តរជាតិពាក់ព័ន្ធកិច្ចការពារកុមាររងគ្រោះ ដោយសារការជួញដូរ ពេស្យាកម្ម និងសម្ភារៈ រូបភាពអាសអាភាសនៃកុមារ » ឱ្យដល់មន្ត្រីមន្ទីរពាក់ព័ន្ធក្នុងខេត្តចំនួន១២ មាន ៖ ខេត្តតាកែវ កំពត ស្វាយរៀង ព្រៃវែង ព្រះសីហនុ កោះកុង កណ្តាល ពោធិសាត់ ប៉ៃលិន បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ សរុបបានចំនួន៣៦០នាក់(ស្រីចំនួន៦៧នាក់) ។
- **ក្រសួងការងារបណ្តុះបណ្តាលនិងវិជ្ជាជីវៈ**នាយកដ្ឋានការងារកុមារ បានសហការជាមួយ អង្គការទស្សនៈពិភពលោកកម្ពុជា ធ្វើការដកហូត និងទប់ស្កាត់ពលកម្មកុមារពីទម្រង់ធ្ងន់ធ្ងរ បានចំនួន ១១៩២នាក់(កុមារី ៥៦០នាក់) ហើយបានបញ្ចូលទៅក្នុងសេវាអប់រំក្រៅប្រព័ន្ធ។
  - កុមារដែលមានអាយុ ១៥-១៧ ឆ្នាំ បានទទួលសេវាបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ២២នាក់
  - គាំទ្រសេវាជីវភាពដល់ឪពុកម្តាយរបស់កុមារ ចំនួន២២២នាក់
- **លេខាធិការដ្ឋាន ប.ជ.រ.ព.ភ ខេត្តឧត្តរមានជ័យ** សហការចុះអធិការកិច្ចមណ្ឌលកុមារកំព្រារបស់អង្គការចំនួន ០២មណ្ឌល គោលបំណងឱ្យមណ្ឌលគោរពតាមគោលការណ៍បទដ្ឋានអប្បរមាក្នុងការថែទាំជំនួសចំពោះកុមារ។
- **លេខាធិការដ្ឋាន ប.ជ.រ.ព.ភខេត្តព្រះសីហនុ** សហការជាមួយអង្គការម្លប់តាប៉ាង រៀបចំបណ្តុះបណ្តាញជួយការពារកុមារ បាន៧០នាក់ និងបណ្តាញសុវត្ថិភាពកុមារបាន១២៨នាក់ ។
- **លេខាធិការដ្ឋាន ប.ជ.រ.ព.ភ ខេត្តកណ្តាល**ចុះសួរសុខទុកកុមារ និងបញ្ជូនទៅរកសេវាគាំទ្រដល់កុមារបានចំនួន១០៧នាក់(កុមារី៥៤នាក់)។

- **លេខាធិការដ្ឋាន ប.ជ.រ.ព.ភ ខេត្តកំពង់ចាម** ចុះអធិការកិច្ចមណ្ឌលគ្រប់គ្រងកុមារ របស់អង្គការចំនួន ០៣ និងចុះធ្វើការផ្ចាកសកម្មភាពមណ្ឌល អង្គការក្តីសង្ឃឹមនៃពលរដ្ឋខ្មែរ ០១ទីតាំង ។
- **លេខាធិការដ្ឋាន ប.ជ.រ.ព.ភ ខេត្តព្រះវិហារ**សហការអង្គការអាស៊ីស្តេកា ពិភាក្សាការងារលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងការងារផ្សេងៗនៅក្នុងមណ្ឌលកុមារ។

**៧- ការងារទេសន្តរប្រវេសន៍:**

- ក្រុមការងារទេសន្តរប្រវេសន៍ ដឹកនាំដោយលោកជំទាវ **ជូ ប៊ុនអេង** ប្រធានលេខាធិការដ្ឋានជាតិដឹកនាំ ប.ជ.រ.ព.ភ និងជាប្រធានក្រុមការងារទេសន្តរប្រវេសន៍ បានដឹកនាំក្រុមការងារបច្ចេកទេសចុះធ្វើការសិក្សាស្រាវជ្រាវភាពប្រឈមនានាទាក់ទងទៅនឹងបញ្ហាទេសន្តរប្រវេសន៍រៀបរយ និងបញ្ហាទេសន្តរប្រវេសន៍មិនទាន់រៀបរយ និងបានរៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ការងារនៅកម្ពុជា ក្នុងគោលបំណងរិះរកវិធានការ យុទ្ធសាស្ត្រជាតិ ដើម្បីការពារធានានូវសុវត្ថិភាពជូនពលករទេសន្តរប្រវេសន៍។
- ក្រុមការងារទេសន្តរប្រវេសន៍ បានដឹកនាំក្រុមការងារចុះទស្សនកិច្ចសិក្សាស្វែងយល់ស្តីពី "ការគ្រប់គ្រងកម្លាំងពលករ និងលំហូរទេសន្តរប្រវេសន៍ ការងារ"នៅក្នុងគោលដៅខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ គោលបំណងឆ្លើយតបទៅ នឹងគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលលេខ០១ គកន ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៣ ដើម្បីរិះរកវិធានការគ្រប់គ្រង និងការពារឱ្យបានច្បាស់លាស់ជូនពលករទេសន្តរប្រវេសន៍ ដែល ចេញតាមប្រព័ន្ធមិនផ្លូវការ ។
- លោកជំទាវប្រធានលេខាធិការដ្ឋានជាតិ បានដឹកនាំក្រុមការងារទេសន្តរប្រវេសន៍ ធ្វើទស្សនកិច្ចសិក្សានិងជួបពិភាក្សាជាមួយក្រុមហ៊ុនជ្រើសរើសពលករចំនួន២១ក្រុមហ៊ុន នៅទីតាំងក្រុមហ៊ុនជ្រើសរើសពលករ **ហ្វីលីម៉រ** ក្នុងគោលបំណង លើកកម្ពស់ការយល់ដឹងអំពីគោលនយោបាយរាជរដ្ឋាភិបាលក្នុងការការពារនិងលើកកម្ពស់សុវត្ថិភាពពលករ និងស្វែងយល់អំពីភាពប្រឈមនានាក្នុងការអនុវត្តច្បាប់ និងគោលនយោបាយដែលក្រុមហ៊ុននានាបាន និងកំពុងអនុវត្តដើម្បីរកដំណោះស្រាយ ព្រមទាំងស្តាប់សំណូមពរផ្សេងៗ។
- ក្រសួងកិច្ចការនារី សហការជាមួយអង្គការ UN Women សិក្សាស្រាវជ្រាវអំពីផលប៉ះពាល់ចំណាកស្រុកនៅក្នុងខេត្តបាត់ដំបង និងធ្វើរបាយការណ៍បញ្ចប់ ។

**ឃ- ការលើកកម្ពស់សមត្ថភាព**

**១. ការបណ្តុះបណ្តាលៈ**

ក្នុងឆ្នាំ២០១៣ កន្លងទៅនេះ ពិនិត្យលើការងារបណ្តុះបណ្តាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងបណ្តាលេខាធិការដ្ឋានថ្នាក់រាជធានី ខេត្តបានសហការជាមួយអង្គការដៃគូមួយចំនួន មានជាអាទិ៍ Winrock International, UNIAP,IJM, World Vision, IOM, ARTIP, SISHA, UNODC, គម្រោង LEAP,APLE,CWCC,CCPCR, Cambodia ACTsនិងមូលនិធិសុម៉ាលីម៉មបានធ្វើការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ មន្ត្រីពាក់ព័ន្ធនិងប្រជាពលរដ្ឋឲ្យយល់ដឹងអំពីច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រាពាក់ព័ន្ធមួយចំនួនក្នុងក្រមព្រហ្មទណ្ឌ យុទ្ធសាស្ត្រប្រឆាំងនឹងអំពើជួញដូរមនុស្ស ជំនាញស្រាវជ្រាវស៊ើបអង្កេត និងការប្រមូលភស្តុតាងសម្រាប់អង្គភាពឯកទេសប្រឆាំងការជួញដូរមនុស្ស ល្បិចកលជនល្មើសការ ស៊ើបអង្កេត ការ

កេងប្រវ័ញ្ចផ្លូវភេទកុមារក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរចំណាកស្រុកដោយសុវត្ថិភាព និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ។ លើសពីនេះទៅទៀត លេខាធិការដ្ឋានជាតិ ប.ជ.រ.ព.ភ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនជាសេនាធិការ បានបណ្តុះបណ្តាលដល់កងកម្លាំងរក្សាសន្តិភាព និងបោសសម្អាតមីនដែលត្រៀមចេញទៅបំពេញបេសកកម្មនៅប្រទេសហ្សកដង់ និងប្រទេសឆាត ចំនួន២២០នាក់ អំពីការងារប្រឆាំងការជួញដូរមនុស្ស និងដើម្បីឲ្យកងកម្លាំងយើងបានយល់ដឹងអំពីច្បាប់ និងការអនុវត្តការបង្ការទប់ស្កាត់បទល្មើសនេះនៅក្នុងប្រទេសគោលដៅ ។

សរុបវគ្គបណ្តុះបណ្តាល បានចំនួន**១៥៨**វគ្គ មានអ្នកចូលរួមសរុបចំនួន៧,៨៨៣នាក់(ស្រី៣,០៣៩នាក់) ។ បើប្រៀបធៀបការបណ្តុះបណ្តាលទៅនឹងឆ្នាំ២០១២ មានការកើនឡើងចំនួន២៧លើក។

**តារាងវគ្គបណ្តុះបណ្តាលៈ**

| ស្ថាប័នអនុវត្ត | ចំនួនវគ្គ | ចំនួនសិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ | ១ | ៣៣ | |
| ក្រសួងកិច្ចការនារី | ៤ | ៦៦១ | ៣៣៣ |
| ក្រុមការងារ COMMIT | ២ | ១០៣ | ៣៦ |
| ក្រសួងទេសចរណ៍ | ១៥ | ៨៦១ | ២៥០ |
| ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | ១២ | ៣៦០ | ៦៧ |
| អគ្គស្នងការដ្ឋាននគរបាលជាតិ | ២០ | ៩៨៣ | ១៤៣ |
| កងរាជអាវុធហត្ថ | ១ | ៤០ | ៨ |
| ខេត្តសៀមរាប | ១០ | ២៤៩ | ៥៨ |
| ខេត្តស្វាយរៀង | ៧ | ៣១០ | ៤០ |
| ខេត្តកំពង់ធំ | ២ | ១០៦ | ៤២ |
| ខេត្តពោធិ៍សាត់ | ១១ | ៤៨៥ | ១៤៤ |
| ខេត្តកំពង់ចាម | ២ | ១៩៧ | ១៤ |
| ខេត្តកំពង់ស្ពឺ | ១ | ៦២ | ២៦ |
| ខេត្តព្រៃវែង | ៤ | ១០៣ | ៧៣ |
| ខេត្តព្រះសីហនុ | ២ | ១៤៤ | ២១ |
| ខេត្តបន្ទាយមានជ័យ | ៣ | ៨៨ | |
| ខេត្តឧត្តរមានជ័យ | ៥ | ៩៦០ | ៦៩៤ |
| ខេត្តព្រះវិហារ | ៥ | ១៩៣ | ៦៦ |

| | | | |
|---|---|---|---|
| ខេត្តកំពង់ឆ្នាំង | ៤៧ | ១,៩៤៥ | ១,០៥០ |
| **សរុប** | **១៥៤** | **៧,៨៨៣** | **៣,០៣៩** |

២. សិក្ខាសាលា

ក្នុងឆ្នាំ២០១៣កន្លងទៅនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធនៅថ្នាក់ជាតិនិងរាជធានី-ខេត្ត បានសហការជាមួយអង្គការដៃគូ មានជាអាទិ៍ Winrock International, UNIAP,IJM,World Vision, IOM,Chab Dai,LAC បើកសិក្ខាសាលាមានដូចជា៖

- ការរៀបចំផែនការយុទ្ធសាស្រ្តជាតិសម្រាប់ការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តរប្រវេសន៍
- ការវាយតម្លៃផែនការអនុវត្តផែនការសកម្មភាព និងការកសាងផែនការអនុវត្តបន្ត
- ការវាយតម្លៃការងារខមមីតកម្ពុជាជាមួយនឹងថ្នាក់តំបន់
- គំរូអនុវត្តសម្រាប់ការគ្រប់គ្រងពលករឆ្លងដែន
- រៀបចំយុទ្ធសាស្រ្តទប់ស្កាត់អំពើជួញដូរមនុស្សឆ្លងដែន
- ការទប់ស្កាត់អំពើជួញដូរមនុស្សថ្នាក់តំបន់
- ការវាយតម្លៃការងារប្រឆាំងការជួញដូរមនុស្សក្នុងមហាអនុតំបន់មេគង្គ (ខមមីត)
- ក្របខ័ណ្ឌច្បាប់ឆ្លើយតបការស៊ើបអង្កេតសម្ងាត់
- កិច្ចគាំពារកុមាររងគ្រោះដោយអំពើជួញដូមនុស្ស និងការរំលោភបំពានផ្សេងៗ
- សុវត្ថិភាពកុមារក្នុងវិស័យទេចរណ៍
- យុត្តិធម៌កុមារប្រព្រឹត្តល្មើសច្បាប់
- ការពិគ្រោះយោបល់រៀបចំទស្សនៈវិស័យរួមគ្នាប្រឆាំងការជួញដូរមនុស្ស

សរុបបានចំនួន**២៧**លើក សិក្ខាកាមចូលរួមមានចំនួន**២,០៨៩**នាក់ (ស្រី៧២៤នាក់)។

បើប្រៀបធៀបការធ្វើសិក្ខាសាលាទៅនឹងឆ្នាំ២០១២ មានការថយចុះចំនួន២៤លើក ប៉ុន្តែចំនួនមនុស្សមានការកើនឡើង ១,២៨៦នាក់ ។

ក្នុងនោះមាន ក្រសួងស្ថាប័នអនុវត្តដូចមានក្នុងតារាងខាងក្រោម ៖

**តារាងវគ្គសិក្ខាសាលា**

| ស្ថាប័នអនុវត្ត | ចំនួនវគ្គ | ចំនួនសិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| លេខាធិការដ្ឋានជាតិដឹកនាំ ប.ជ.រ.ព.ភ | ៥ | ៨០៤ | ២៧០ |
| ក្រសួងយុត្តិធម៌ | ១ | ១១០ | |
| អគ្គស្នងការនគរបាល/ក្រសួងមហាផ្ទៃ | ១ | ៣៩ | ១៨ |
| ក្រុមការងារ COMMIT កម្ពុជា | ៣ | ៩៦ | ៤០ |
| ក្រសួងទេសចរណ៍ | ២ | ៩៨ | ៤០ |

| | | | |
|---|---|---|---|
| ក្រសួងកិច្ចការនារី | ២ | ១៣៩ | ៥៧ |
| ខេត្តបន្ទាយមានជ័យ | ១ | ៣០ | |
| ខេត្តបាត់ដំបង | ១ | ៣៥ | ៦ |
| ខេត្តព្រះសីហនុ | ១ | ៣៩ | |
| ខេត្តកំពង់ធំ | ២ | ២៤០ | ១០៨ |
| ខេត្តកោះកុង | ២ | ៦៩ | ១៥ |
| ខេត្តព្រះវិហារ | ១ | ៤១ | ៨ |
| ខេត្តសៀមរាប | ៤ | ៣១៦ | ១៦២ |
| រាជធានីភ្នំពេញ | ១ | ៣៣ | |
| **សរុប** | **២៧** | **២,០៨៩** | **៧២៤** |

## III- ការសន្និដ្ឋាន វាយតម្លៃលើលទ្ធផលសកម្មភាពឆ្នាំ ២០១៣ :

ជាទូទៅ លទ្ធផលដែលទទួលបានក្នុងឆ្នាំ២០១៣កន្លងទៅនេះ អាចឲ្យយើងសន្និដ្ឋានបានថា៖

**ក. ចំណុចខ្លាំង:**

១. រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តប្តេជ្ញាចិត្តខ្ពស់ប្រឆាំងទៅនឹងអំពើជួញដូរមនុស្ស អំពើអាជីវកម្មផ្លូវភេទ និងអំពើកេងប្រវ័ញ្ចផ្សេងៗទៀតលើមនុស្ស ដោយចាត់ទុកជាបទឧក្រិដ្ឋយ៉ាងធ្ងន់ធ្ងរ និងមិនបណ្តែតបណ្តោយឲ្យចារី និងសហចារីដែលបានប្រព្រឹត្ត រួចផុតពីការផ្តន្ទាទោសដោយមិនបានចាត់វិធានការទៅតាមនីតិវិធីច្បាប់នោះឡើយ ។

២. រាជរដ្ឋាភិបាលកម្ពុជា បានអនុម័តច្បាប់ថ្មីស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលឆ្លើយតបទៅនឹងបទដ្ឋានអន្តរជាតិ និងមានយន្តការជាតិ ដែលមានរចនាសម្ព័ន្ធទូលំទូលាយដល់ថ្នាក់ក្រោមជាតិ ហើយបាន និងកំពុងតែមានទំនាក់ទំនងសហការល្អជាមួយប្រទេសក្នុងតំបន់ និងជាអន្តរជាតិ ។

៣. មានការយល់ដឹងកាន់តែល្អប្រសើរ អំពីសារៈសំខាន់នៃកិច្ចសហការរវាងគ្រប់ដៃគូពាក់ព័ន្ធគ្រប់ផ្នែក គ្រប់វិស័យ ទាំងក្នុងរាជរដ្ឋាភិបាល ទាំងអង្គការមិនមែនរដ្ឋាភិបាល និងផ្នែកឯកជន ក្នុងការប្រយុទ្ធប្រឆាំងនិងបង្ក្រាបនូវអំពើជួញដូរមនុស្សនៅក្នុងប្រទេស ក្នុងអនុតំបន់ ក្នុងតំបន់ និងជាអន្តរជាតិ ។

៣. មានផែនការជាតិ និងទិសដៅការងារសម្រាប់អនុវត្តដែលជាផែនទីបង្ហាញផ្លូវ ។

៤. មានកិច្ចព្រមព្រៀង អនុស្សរណៈនៃការយោគយល់គ្នារវាងប្រទេសពាក់ព័ន្ធ និងបានសហការជាមួយបណ្តាសមត្ថកិច្ចក្នុងតំបន់និងអន្តរជាតិ មានទំនាក់ទំនងល្អជាមួយរដ្ឋាភិបាលនិងស្ថានទូតប្រទេសពាក់ព័ន្ធ ដើម្បីធ្វើប្រតិបត្តិការរួមគ្នាក្នុងការស្វែងរកជនល្មើស សង្គ្រោះជនរងគ្រោះ និងបញ្ជូនជនរងគ្រោះមកមាតុភូមិវិញដោយសុវត្ថិភាព ។

៤. លទ្ធផលជាវិជ្ជមានដែលគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ សម្រេចបានក្នុងឆ្នាំ ២០១៣ គឺបានបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការ និងលេខាធិការដ្ឋានថ្នាក់ជាតិ និងរាជធានីខេត្ត ព្រមទាំងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ក៏ដូចជាអង្គការដៃគូជាតិ និងអន្តរជាតិ ដែលបានរួមគ្នាប្រឹងប្រែងអនុវត្ត ដែលទោះបីជាមិនទាន់មានភាពរលូន ឬមិនទាន់ទទួលបានលទ្ធផលល្អដូចការរំពឹងទុកក៏ដោយ តែបានធ្វើ

ឲ្យជនល្មើសមានការខ្លាចរអារ និងមិនមានបង្ហាញឲ្យឃើញអំពីភាពលេចធ្លោនៃបទល្មើសជួញដូរមនុស្ស នោះឡើយ ។

***ខ. ចំណុចសេសសល់និងភាពប្រឈម:***

ទោះបីជាមានចំណុចខ្លាំងដូចបានរៀបរាប់ខាងលើនេះក្តី ក៏នៅមានចំណុចសេសសល់និងភាពប្រឈមមួយចំនួន ដែលត្រូវយកចិត្តទុកដាក់រិះរកវិធានការបំពេញបន្ថែម គឺ ៖

១. ការវិវត្តប្រែប្រួលនៃបទល្មើស និងល្បិចកលជនល្មើស ព្រមទាំងទំនោរចំណាកស្រុករបស់ប្រជាពលរដ្ឋ និងការទាក់ទាញពលករឲ្យទៅធ្វើការងារដោយខុសច្បាប់ក្នុងប្រទេសមួយចំនួន ទាមទារឲ្យមានវិធានការសមស្រប និងយុទ្ធសាស្ត្រថ្មីៗ ដើម្បីឆ្លើយតបឲ្យទាន់សភាពការណ៍ និងអាចបង្ក្រាបបទល្មើសដែលកំពុងជ្រកក្រោមរូបភាពចំណាកស្រុក ។

២. ថ្វីត្បិតតែគ្រប់ក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធទាំងឡាយបាន និងកំពុងតែប្រឹងប្រែងបំពេញភារកិច្ចយ៉ាងសកម្មក្នុងការបង្ការទប់ស្កាត់ ការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការបង្ក្រាប និងសង្គ្រោះ ការផ្តន្ទាទោស ការពង្រឹងកិច្ចសហការក្នុងនិងក្រៅប្រទេស តែកិច្ចសហប្រតិបត្តិការរវាងស្ថាប័ននីមួយៗមិនទាន់ល្អប្រសើរនៅឡើយ ទាំងក្នុងកិច្ចប្រតិបត្តិការ ទាំងការផ្លាស់ប្តូរព័ត៌មាន និងរបាយការណ៍លទ្ធផលការងារ ។

៣. កង្វះធនធានគាំទ្រធ្វើឲ្យការបូកសរុបរបាយការណ៍នៃកិច្ចការផ្តន្ទាទោសមានភាពយឺតយ៉ាវ មិនបានទៀងទាត់ ដែលធ្វើឲ្យការបូកសរុប និងវាយតម្លៃជួបការលំបាក និងជះឥទ្ធិពលដល់ការវាយតម្លៃលើប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការប្រឆាំងការជួញដូរមនុស្ស ពីមជ្ឈដ្ឋានខាងក្រៅ ។

៤. ការចុះតាមដានត្រួតពិនិត្យ និងគាំទ្រសកម្មភាពដល់រាជធានីខេត្តជាកិច្ចការដ៏សំខាន់ តែលេខាធិការដ្ឋានមិនមានកម្លាំង ធនធាន និងពេលវេលាគ្រប់គ្រាន់សម្រាប់ធ្វើកិច្ចការនេះនៅឡើយ ។

៥. សកម្មភាពការងារ និងរបាយការណ៍ពីក្រុមការងារ និងលេខាធិការដ្ឋានតាមបណ្តាថ្នាក់មួយចំនួនហាក់ដូចជាមានការយឺតយ៉ាវ មិនសូវសកម្ម ជាពិសេសបន្ទាប់ពីមានការផ្លាស់ប្តូរសមាសភាពមន្ត្រីពាក់ព័ន្ធក្នុងរាជរដ្ឋាភិបាលមួយចំនួន ។

៦. អនុស្សរណៈនិងកិច្ចព្រមព្រៀងជាមួយប្រទេសពាក់ព័ន្ធដូចជាប្រទេសថៃ និងម៉ាលេស៊ី មានការយឺតយ៉ាវក្នុងការឆ្លើយតប ដែលនាំឲ្យការអនុវត្តមានភាពរាំងស្ទះ និងនៅតែបន្តមានពលករចេញទៅដោយខុសច្បាប់។

៧. ការស្នើសុំធនធានថវិកាជាតិ សម្រាប់ការអនុវត្តសកម្មភាពនៅគ្រប់កម្រិត នៅមិនទាន់អាចអនុវត្តបាន ដែលជាហេតុនាំឲ្យសកម្មភាពមានភាពរអាក់រអួល ហើយរំពឹងភាគច្រើនលើការជួយឧបត្ថម្ភគាំទ្រពីអង្គការដៃគូដែលមានកម្រិត និងមិនទៀងទាត់ ។

៨. ផែនការសកម្មភាពជាតិត្រូវបានបញ្ចប់ក្នុងឆ្នាំ២០១៣និងត្រូវការការរៀបចំជំហានបន្ត ។

***គ. ការសន្និដ្ឋាន វាយតម្លៃ:***

ពិនិត្យលើចំណុចខ្លាំងចំណុចសេសសល់និងចំណុចប្រឈម ដែលបានឆ្លុះបញ្ចាំង និងរៀបរាប់ខាងលើនេះ យើងអាចទាញជាការសន្និដ្ឋាន និងវាយតម្លៃបាន ជាគន្លឹះ ដូចខាងក្រោម ៖

១. ដើម្បីកែលំអការគ្រប់គ្រង កិច្ចសហប្រតិបត្តិការ និងមានការឯកភាពគ្នាក្នុងការអនុវត្តភារកិច្ច ទាមទារឲ្យរៀបចំជាបន្ទាន់នូវរចនាសម្ព័ន្ធនៃយន្តការគ្រប់ថ្នាក់ និងពង្រឹងរបៀបរបបការងារឡើងវិញ ។

២. ត្រូវការឲ្យមានគោលដៅ និងយុទ្ធសាស្ត្រជាក់លាក់ក្នុងការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស

និងការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ ការកំណត់យុទ្ធសាស្ត្ររួមថ្នាក់ជាតិ ដើម្បីការងារបង្ការទប់ស្កាត់ ការងារជួយជនរងគ្រោះទាំងក្នុង និងក្រៅប្រទេស និងត្រូវរៀបចំបន្តនូវផែនការសកម្មភាពជាតិ ដែលត្រូវបញ្ចប់នៅក្នុងឆ្នាំ២០១៣ ។

៣. ទាមទារឲ្យជម្រុញ និងតាមដានការអនុវត្តគោលការណ៍ណែនាំ លេខ ០១គកន របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី០៥ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តរប្រវេសន៍ ។

៤. ត្រូវការការពង្រឹងសមត្ថភាពមន្ត្រីក្នុងរចនាសម្ព័ន្ធគ្រប់ថ្នាក់ និងរៀបចំគោលការណ៍ ឯកសារដែលមានលក្ខណៈស្តង់ដា និងជាប្រព័ន្ធ សម្រាប់ការបណ្តុះបណ្តាល ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តគ្រប់ថ្នាក់ ។

៥. ទាមទារឲ្យមានការផ្សព្វផ្សាយទូលំទូលាយដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់ឲ្យមានការយល់ដឹងអំពី ផលវិបាកនៃភាពប្រថុយប្រថានក្នុងការធ្វើចំណាកស្រុក ដែលមិនមានការធានាផ្នែកច្បាប់ ។

៦. ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការផ្ទៃក្នុង និងជាមួយប្រទេសនានាជាប់ព្រំដែន ក្នុងតំបន់ និងជាអន្តរជាតិ ដើម្បីរួមគ្នាទប់ស្កាត់បទល្មើសជួញដូរមនុស្ស ការប្រើប្រាស់កម្លាំងពលកម្មដោយខុសច្បាប់ និងការការពារសិទ្ធិ ផលប្រយោជន៍ និងសុវត្ថិភាពរបស់ពលករ និងជនរងគ្រោះ ។

## IV- <u>**ទិសដៅសម្រាប់អនុវត្តឆ្នាំ២០១៤**</u>:មាន៣០ចំណុច និងចែកចេញជា ០៧គោលដៅ ៖

ក. <u>ការងារច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្ត ៖</u>

១- ជម្រុញ និងតាមដានការអនុម័តច្បាប់ស្តីអំពីអំពើរត់ពន្ធមនុស្ស និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធមួយចំនួនសម្រាប់ជាវិធានការច្បាប់ចំពោះបទល្មើសពាក់ព័ន្ធអំពើរត់ពន្ធមនុស្ស ។

២- ជម្រុញការរៀបចំព្រះរាជក្រឹត្យ និងអនុក្រឹត្យ និងឯកសារគតិយុត្តិពាក់ព័ន្ធនឹងការកែសម្រួលរចនាសម្ព័ន្ធនៃយន្តការប្រយុទ្ធប្រឆាំងការជួញដូរមនុស្សថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋានថ្នាក់ជាតិ និងលេខាធិការដ្ឋានថ្នាក់រាជធានី ខេត្ត ឲ្យបានឆាប់ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច ។

៣- ជម្រុញការរៀបចំនីតិវិធីគ្រប់គ្រងដែលមានលក្ខណៈជាប្រព័ន្ធ ដើម្បីជម្រុញការអនុវត្តគោលការណ៍ណែនាំលេខ ០១គកន របស់រាជរដ្ឋាភិបាលស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តរប្រវេសន៍។

៤- រៀបចំគោលការណ៍ណែនាំ អនុវត្ត បទបញ្ញត្តិ ពាក់ព័ន្ធការស៊ើបអង្កេតសម្ងាត់ ។

៥- ជម្រុញឱ្យមាននីតិវិធីដើម្បីផ្តល់នីតិសម្បទាផ្លូវច្បាប់ដល់មណ្ឌលអង្គការដៃគូដែលជួយគាំទ្រដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

៦- ជម្រុញការរៀបចំ បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

ខ. <u>**ការងារផែនការ៖**</u>

១- រៀបចំផែនការសកម្មភាពជាតិលើកទី២ដើម្បីអនុវត្តបន្តសម្រាប់ឆ្នាំ២០១៤-២០១៨ និងរៀបចំយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងបញ្ហាទេសន្តរប្រវេសន៍ការងារដើម្បីឲ្យមានសុវត្ថិភាព ។

២- រៀបចំផែនការ និងយុទ្ធសាស្ត្របង្ការ ទប់ស្កាត់ថ្នាក់ជាតិដើម្បីអនុវត្តជាប្រព័ន្ធ ។

៣- រៀបចំផែនការបន្ត សម្រាប់ការអនុវត្តនៅគ្រប់ថ្នាក់ និងផែនការតាមដានត្រួតពិនិត្យ ។

៤- គាំទ្រការរៀបចំផែនការសម្រាប់ការងារថ្នាក់តំបន់ ដើម្បីឲ្យស៊ីចង្វាក់ជាមួយគ្នា ជាមួយថ្នាក់ជាតិ សម្រាប់ការអនុវត្តអនុស្សរណៈកិច្ចព្រមព្រៀងទ្វេភាគី និង ពហុភាគីនានា ។

NATIONAL COMMITTEE TO LEAD

គ. ការងារអប់រំផ្សព្វផ្សាយ៖

១- ផ្សព្វផ្សាយរបាយការណ៍បូកសរុបដកពិសោធន៍ការងារបង្ការ-ទប់ស្កាត់បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ របស់គណៈកម្មាធិការជាតិប.ជ.រ.ព.ភ ឆ្នាំ២០១៣ និងទិសដៅ ឆ្នាំ២០១៤ ។

២- ផ្សព្វផ្សាយការយល់ដឹងការអនុវត្តនីតិវិធីជំនួយផ្នែកច្បាប់ឲ្យគ្នាទៅវិញទៅមក រវាងប្រទេសក្នុងសហគមន៍អាស៊ានលើរឿងក្តីព្រហ្មទណ្ឌ ជាពិសេសរឿងក្តីទាក់ទងនឹងអំពើជួញដូរមនុស្ស ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការជួយជនរងគ្រោះដល់មន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ ។

៣- ជម្រុញការផ្សព្វផ្សាយប្រកាសចំនួន ០៨សម្រាប់ការអនុវត្តអនុក្រឹត្យលេខ១៩០ អនក្រ.បក ស្តីពីការគ្រប់គ្រងពលករទេសន្តរប្រវេសន៍ ឲ្យបានទូលំទូលាយ ។

៤- បន្តរៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយ តាមរយៈ ៨ទិកាជាតិ ១២ធ្នូ ប្រឆាំងការជួញដូរមនុស្ស ។

ឃ. ការងារអភិវឌ្ឍន៍ធនធានមនុស្ស៖

១- រៀបចំសមាសភាព និងរបៀបរបបការងារអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ និងលេខាធិការដ្ឋានរាជធានី ខេត្ត

២- ពង្រឹងសមត្ថភាពមន្ត្រីក្នុងអគ្គលេខាធិការដ្ឋាន លេខាធិការដ្ឋាន និងមន្ត្រីទទួលបន្ទុកការងារប្រឆាំងការជួញដូរមនុស្ស គ្រប់ថ្នាក់ឲ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញភារកិច្ចប្រកបដោយការទទួលខុសត្រូវ និងទទួលបានប្រសិទ្ធភាពខ្ពស់ ។

៣- ពង្រឹងសមត្ថភាពផ្នែកច្បាប់ ដល់មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងតុលាការនៅទូទាំងប្រទេស ។

៤- ជម្រុញការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ទប់ស្កាត់ការជួញដូរមនុស្ស និងបណ្តុះបណ្តាលស្តីពីយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស។

៥- ជម្រុញការធ្វើសិក្ខាសាលា ឆ្លើយតបទៅនឹងផែនការសកម្មភាពការងារ ប.ជ.រ.ព.ភ របស់ស្ថាប័នពាក់ព័ន្ធ

ង.ការងារជម្រុញការអនុវត្ត៖

១- ជម្រុញ និងលើកកម្ពស់ការអនុវត្តសកម្មភាពប្រឆាំងការជួញដូរមនុស្ស តាមរយៈការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងលើកកម្ពស់ការចូលរួមពីប្រជាពលរដ្ឋក្នុងការបង្ការ-ទប់ស្កាត់ ការផ្តល់ពត៌មាន និងវិធានការបង្ក្រាបបទល្មើសជួញដូរមនុស្ស និងការការពារកុមារពីភាពរងគ្រោះដោយទេសចរណ៍ផ្លូវភេទ ។

២- ពង្រឹងការអនុវត្តវិធានការគ្រប់គ្រងរបស់សមត្ថកិច្ចមូលដ្ឋាន សមត្ថកិច្ចការពារព្រំដែន ដោយសហការឲ្យបានល្អជាមួយសមត្ថកិច្ចប្រទេសជិតខាង ដើម្បីបង្ការនិង បង្ក្រាបបទល្មើសជួញដូរមនុស្ស និងការរត់ពន្ធមនុស្សឆ្លងកាត់ព្រំដែនគោក ព្រំដែនទឹក និងព្រំដែនអាកាស។

៣- ពង្រឹងការអនុវត្តយុទ្ធសាស្ត្រ បង្ការទប់ស្កាត់ បង្ក្រាប ផ្តន្ទាទោស និងជួយជនរងគ្រោះ ឲ្យមានប្រសិទ្ធិភាព ។

៤- ជម្រុញការធ្វើអធិការកិច្ចការងារពលកម្មកុមារ នៅតាមបណ្តារោងចក្រ សហគ្រាស និងសិប្បកម្មនានា ដើម្បីឆ្លើយតបទៅនឹងកិច្ចការពារកុមារ ។

៥- ជម្រុញការអនុវត្តគោលការណ៍ណែនាំរាជរដ្ឋាភិបាល លេខ០១ គកន. ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១៤ ស្តីពី ការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តរប្រវេសន៍ ផែនការសកម្មភាពជាតិ និងរាជធានីខេត្ត ព្រមទាំងជម្រុញការអនុវត្តច្បាប់ និងគោលនយោបាយពាក់ព័ន្ធនានា ។

ច. ការពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូ៖

១- ពង្រឹង និងពង្រីកកិច្ចសហការជាមួយដៃគូជាតិ អន្តរជាតិ និងប្រទេសពាក់ព័ន្ធ ដើម្បីរួមគ្នាបង្កើត កែលំអ និងអនុវត្តសកម្មភាពដើម្បីធ្វើឲ្យសម្រេចគោលដៅតាមការគ្រោងទុក ជាពិសេស ជម្រុញអនុវត្តកិច្ចព្រមព្រៀង និងអនុស្សរណៈទ្វេភាគី ពហុភាគីឲ្យមានប្រសិទ្ធភាព ។

២- ជម្រុញការចុះហត្ថលេខា លើការកែសម្រួលអនុស្សរណៈនៃការយោគយល់គ្នា រវាងកម្ពុជា ថៃ ។

៣- បន្តកិច្ចសហប្រតិបត្តិការដើម្បីពិនិត្យបញ្ចប់អនុស្សរណៈនៃការយោគយល់គ្នា រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសម៉ាឡេស៊ី និងជាមួយប្រទេសចិន ។

៤- ត្រៀមរៀបចំ កិច្ចប្រជុំកំពូលរវាងប្រទេសមហាអនុតំបន់មេគង្គ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**ឆ. ការងារតាមដានត្រួតពិនិត្យ៖**

១- តាមដានប្រសិទ្ធភាពនៃការអនុវត្តបទដ្ឋាន ច្បាប់ គោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រនានា ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធមួយចំនួន សម្រាប់ជាវិធានការច្បាប់ចំពោះបទល្មើសពាក់ព័ន្ធអំពើរត់ពន្ធមនុស្ស ។

២- សិក្សាអំពីភាពបត់បែននៃបទល្មើស ដើម្បីរៀបចំយុទ្ធសាស្ត្រជាតិ សម្រាប់ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស ការជួយជនរងគ្រោះ និងការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ដែលកំពុងស្ថិតនៅក្រៅប្រព័ន្ធនៃការគ្រប់គ្រងដោយស្របច្បាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធានគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ**

ស ខេង

**កន្លែងទទួល៖**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-សមាជិកគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ភ
-សមាជិកលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិដឹកនាំប.ជ.រ.ព.ភ
-គណៈកម្មាធិការដឹកនាំ និងលេខាធិការដ្ឋាន ប.ជ.រ.ព.ភ ថ្នាក់រាជធានី-ខេត្ត
-អង្គការដៃគូអភិវឌ្ឍន៍
«ដើម្បីជូនជ្រាបជារបាយការណ៍»
-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ត

លេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងទិន្នន័យបង្ក្រាបបទល្មើស អំពើជួញដូរមនុស្ស

(គិតពីថ្ងៃទី២៦/១២/២០១២ ដល់ថ្ងៃទី២៥/១២/២០១៣) ឆ្នាំ២០១៣

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | បង្ក្រាបសរុប: ករណីបង្ក្រាប | ជនរងគ្រោះ | ជនល្មើស | ជនរងគ្រោះ 15 | ជនរងគ្រោះ 15-17 | ជនរងគ្រោះ 18 | ជនល្មើស ប | ជនល្មើស ស |
|---|---|---|---|---|---|---|---|---|---|
| 1 | នាយកដ្ឋាន | 6 | 7 | 8 | 3 | 1 | 3 | 4 | 4 |
| 2 | រាជធានីភ្នំពេញ | 7 | 15 | 15 | 3 | 2 | 10 | 7 | 8 |
| 3 | សៀមរាប | 3 | 4 | 4 | 2 |  | 2 | 2 | 2 |
| 4 | បន្ទាយមានជ័យ | 1 | 1 | 1 | 1 |  |  |  | 1 |
| 5 | កណ្ដាល | 1 | 1 | 1 | 1 |  |  |  | 1 |
| 6 | បាត់ដំបង | 3 | 8 | 3 |  | 3 | 5 | 3 |  |
| 7 | ព្រះសីហនុ | 1 | 4 | 1 | 4 |  |  | 1 |  |
| 8 | កំពង់ឆ្នាំង |  |  |  |  |  |  |  |  |
| 9 | កំពង់ចាម | 1 | 2 | 1 |  | 2 |  |  | 1 |
| 10 | កំពង់ស្ពឺ |  |  |  |  |  |  |  |  |
| 11 | ព្រះវិហារ |  |  |  |  |  |  |  |  |
| 12 | កំពត | 1 |  | 1 |  |  |  | 1 |  |
| 13 | ស្ទឹងត្រែង | 1 | 2 | 2 |  |  | 2 | 1 | 1 |
| 14 | កែប |  |  |  |  |  |  |  |  |
| 15 | ក្រចេះ |  |  |  |  |  |  |  |  |
| 16 | តាកែវ |  |  |  |  |  |  |  |  |
| 17 | ប៉ៃលិន |  |  |  |  |  |  |  |  |
| 18 | ពោធិ៍សាត់ |  |  |  |  |  |  |  |  |
| 19 | ព្រៃវែង | 1 | 12 | 1 |  |  | 12 | 1 |  |
| 20 | ស្វាយរៀង | 4 | 10 | 5 |  | 4 | 6 | 5 |  |
| 21 | រតនៈគិរី |  |  |  |  |  |  |  |  |
| 22 | មណ្ឌលគិរី |  |  |  |  |  |  |  |  |
| 23 | កោះកុង |  |  |  |  |  |  |  |  |
| 24 | កំពង់ធំ |  |  |  |  |  |  |  |  |
| 25 | ឧត្តរមានជ័យ | 2 | 9 | 2 |  |  | 9 | 1 | 1 |
| 26 | QNច្នេប្រទេស | 2 | 13 | 2 |  |  | 13 | 2 |  |
|  | សរុបរួម | 34 | 88 | 47 | 14 | 12 | 62 | 28 | 19 |

| ល.រ | រាជធានី ខេត្ត | មាត្រា០៨ ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់: ករណីបង្ក្រាប | ជនរងគ្រោះ 15 | 15-17 | 18 | ជនល្មើស ប | ស | មាត្រា១០ ការនាំចេញដោយមិនស្របច្បាប់ដោយមានគោលដៅ: ករណីបង្ក្រាប | ជនរងគ្រោះ 15 | 15-17 | 18 | ជនល្មើស ប | ស | មាត្រា១១ ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន: ករណីបង្ក្រាប | ជនរងគ្រោះ 15 | 15-17 | 18 | ជនល្មើស ប | ស | មាត្រា១២ ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច: ករណីបង្ក្រាប | ជនរងគ្រោះ 15 | 15-17 | 18 | ជនល្មើស ប | ស | មាត្រា១៤ =(១៣) អំពើលក់ដូរ-មនុស្ស: ករណីបង្ក្រាប | ជនរងគ្រោះ 15 | 15-17 | 18 | ជនល្មើស ប | ស |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | នាយកដ្ឋាន |  |  |  |  |  |  | 3 |  |  | 3 | 2 | 3 |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 2 | រាជធានីភ្នំពេញ |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  | 1 |  |  | 2 | 1 | 2 |
| 3 | សៀមរាប |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 4 | បន្ទាយមានជ័យ | 1 | 1 |  |  |  | 1 |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 5 | កណ្ដាល |  |  |  |  |  |  |  |  |  |  |  |  | 1 | 1 |  |  |  | 1 |  |  |  |  |  |  |  |  |  |  |  |  |
| 6 | បាត់ដំបង |  |  |  |  |  |  | 3 |  | 3 | 5 | 3 |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 7 | ព្រះសីហនុ |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 8 | កំពង់ឆ្នាំង |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 9 | កំពង់ចាម |  |  |  |  |  |  |  |  |  |  |  |  | 1 |  | 2 |  |  | 1 |  |  |  |  |  |  |  |  |  |  |  |  |
| 10 | កំពង់ស្ពឺ |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 11 | ព្រះវិហារ |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 12 | កំពត |  |  |  |  |  |  |  |  |  |  |  |  | 1 |  |  |  | 1 |  |  |  |  |  |  |  |  |  |  |  |  |  |
| 13 | ស្ទឹងត្រែង |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  | 1 |  |  | 2 | 1 | 1 |  |  |  |  |  |  |
| 14 | កែប |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 15 | ក្រចេះ |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 16 | តាកែវ |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 17 | ប៉ៃលិន |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 18 | ពោធិ៍សាត់ |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 19 | ព្រៃវែង |  |  |  |  |  |  |  |  |  |  |  |  | 1 |  |  | 12 | 1 |  |  |  |  |  |  |  |  |  |  |  |  |  |
| 20 | ស្វាយរៀង |  |  |  |  |  |  | 2 |  | 1 | 1 | 2 |  | 2 |  | 3 | 5 | 3 |  |  |  |  |  |  |  |  |  |  |  |  |  |
| 21 | រតនៈគិរី |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 22 | មណ្ឌលគិរី |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 23 | កោះកុង |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 24 | កំពង់ធំ |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| 25 | ឧត្តរមានជ័យ |  |  |  |  |  |  |  |  |  |  |  |  | 1 |  |  | 8 | 1 |  |  |  |  |  |  |  |  |  |  |  |  |  |
| 26 | QNច្នេប្រទេស |  |  |  |  |  |  |  |  |  |  |  |  | 2 |  |  | 13 | 2 |  |  |  |  |  |  |  |  |  |  |  |  |  |
|  | សរុបរួម | 1 | 1 |  |  |  | 1 | 8 |  | 4 | 9 | 7 | 3 | 9 | 1 | 5 | 38 | 8 | 2 | 1 |  |  | 2 | 1 | 1 | 1 |  |  | 2 | 1 | 2 |

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | មាត្រា១៥ អំពើលក់-ដូរមនុស្ស ដោយមានគោលដៅ | | | | | | មាត្រា១៦ អំពើលក់-ដូរមនុស្ស សម្រាប់នាំឆ្លងដែន | | | | | | មាត្រា១៧ ការដឹកជញ្ជូន ដោយមានគោលដៅ | | | | | | មាត្រា១៩ ការទទួលយកមនុស្ស ដោយមានគោលដៅ | | | | | | មាត្រា២១ ការចាប់ពង្រត់-ការឃុំឃាំង រឺ បង្ខាំង | | | | | | មាត្រា៣៤ ការទិញសេវាផ្លូវភេទកុមារ | | | | | មាត្រា៣៥ អំពើអួសទាញ ពេស្យាចារកុមារ | | | | | | ជនរងគ្រោះ បញ្ជូនទៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណីប្រព្រឹត្ត | ជនរងគ្រោះ | | | ជនល្មើស | | ករណីប្រព្រឹត្ត | ជនរងគ្រោះ | | | ជនល្មើស | | ករណីប្រព្រឹត្ត | ជនរងគ្រោះ | | | ជនល្មើស | | ករណីប្រព្រឹត្ត | ជនរងគ្រោះ | | | ជនល្មើស | | ករណីប្រព្រឹត្ត | ជនរងគ្រោះ | | | ជនល្មើស | | ករណីប្រព្រឹត្ត | ជនរងគ្រោ | | ជនល្មើស | | ករណីប្រព្រឹត្ត | ជនរងគ្រោះ | | | ជនល្មើស | | | | |
| | | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | ប | ស | | -15 | 15-17 | 18 | ប | ស | សង | អង | គ្រស |
| 1 | នាយកដ្ឋាន | 2 | 3 | | | 1 | 1 | | | | | | | | | | | | | | | | | | | | | | | | | 1 | | 1 | | | | | | | | | 3 | 1 | 3 |
| 2 | រាជធានីភ្នំពេញ | 1 | | 2 | | | 3 | 3 | | | 5 | 4 | 2 | | | | | | | 1 | 1 | | 3 | 1 | 1 | | | | | | | 1 | 2 | | | | | | | | | | 3 | | 12 |
| 3 | សៀមរាប | | | | | | | 1 | | | 2 | | 2 | | | | | | | | | | | | | | | | | | | 2 | 2 | | 2 | | | | | | | | 3 | | 1 |
| 4 | បន្ទាយមានជ័យ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 |
| 5 | កណ្តាល | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 |
| 6 | បាត់ដំបង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 8 |
| 7 | ព្រះសីហនុ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 1 | 4 | | 1 | | | | | | | | 4 | | |
| 8 | កំពង់ឆ្នាំង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 9 | កំពង់ចាម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 2 |
| 10 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 11 | ព្រះវិហារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 12 | កំពត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 13 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 2 |
| 14 | កែប | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 15 | ក្រចេះ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 16 | តាកែវ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 17 | ប៉ៃលិន | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 18 | ពោធិ៍សាត់ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 19 | ព្រៃវែង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 12 |
| 20 | ស្វាយរៀង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 10 |
| 21 | រតនៈគិរី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 22 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 23 | កោះកុង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 24 | កំពង់ធំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 25 | ឧត្តរមានជ័យ | | | | | | | 1 | | | 1 | | 1 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 9 |
| 26 | ព្រះវិហារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | 13 |
| | **សរុបរួម** | 3 | 3 | 2 | | 1 | 4 | 5 | | | 8 | 4 | 5 | | | | | | | 1 | 1 | | 3 | 1 | 1 | | | | | | | 5 | 8 | 1 | 5 | | | | | | | | 13 | 1 | 74 |

**សគ: មន្ទីរសង្គមកិច្ចរាជធានី-ខេត្ត**　　**អភ: អង្គការក្រៅរដ្ឋាភិបាល**　　**គ្រស: គ្រួសារ ឬ អាណាព្យាបាល**

គណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ត

លេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងទិន្នន័យបទល្មើសបង្ក្រាប អំពើរធ្វើអាជីវកម្មផ្លូវភេទ

(គិតពីថ្ងៃទី២៦/១២/២០១២ ដល់ថ្ងៃទី២៥/១២/២០១៣) ឆ្នាំ២០១៣

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | បង្ក្រាបសរុប: ករណីបង្ក្រាប | ជនរងគ្រោះ | ជនល្មើស | អាយុជនរងគ្រោះ <១៥ | អាយុជនរងគ្រោះ ១៥-១៧ | អាយុជនរងគ្រោះ ≥១៨ | ជនល្មើស ប | ជនល្មើស ស | មាត្រា២១ ការចាប់ពង្រត់ ការឃុំឃាំង រឺ បង្ខាំង: ករណីបង្ក្រាប | ជនរងគ្រោះ <១៥ | ជនរងគ្រោះ ១៥-១៧ | ជនរងគ្រោះ ≥១៨ | ជនល្មើស ប | ជនល្មើស ស |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | នាយកដ្ឋាន | 8 | 73 | 15 | 19 | 28 | 26 | 9 | 6 | | | | | | |
| ២ | រាជធានីភ្នំពេញ | 19 | 68 | 20 | 12 | 4 | 52 | 15 | 5 | | | | | | |
| ៣ | សៀមរាប | 3 | 7 | 5 | 3 | | 4 | 2 | 3 | | | | | | |
| ៤ | បន្ទាយមានជ័យ | 5 | 17 | 5 | 3 | | 14 | 4 | 1 | | | | | | |
| ៥ | កណ្តាល | 2 | 3 | 3 | 2 | 1 | | 2 | 1 | | | | | | |
| ៦ | បាត់ដំបង | 6 | 10 | 6 | 7 | 2 | 1 | 6 | | | | | | | |
| ៧ | ព្រះសីហនុ | 4 | 9 | 5 | 4 | 1 | 4 | 4 | 1 | | | | | | |
| ៨ | កំពង់ឆ្នាំង | 2 | 5 | 2 | 1 | | 4 | 2 | | | | | | | |
| ៩ | កំពង់ចាម | 4 | 4 | 4 | 4 | | | 4 | | | | | | | |
| ១០ | កំពង់ស្ពឺ | | | | | | | | | | | | | | |
| ១១ | ព្រះវិហារ | | | | | | | | | | | | | | |
| ១២ | កំពត | 3 | 4 | 3 | 4 | | | 3 | | | | | | | |
| ១៣ | ស្ទឹងត្រែង | | | | | | | | | | | | | | |
| ១៤ | កែប | | | | | | | | | | | | | | |
| ១៥ | ក្រចេះ | | | | | | | | | | | | | | |
| ១៦ | តាកែវ | | | | | | | | | | | | | | |
| ១៧ | ប៉ៃលិន | | | | | | | | | | | | | | |
| ១៨ | ពោធិ៍សាត់ | 1 | 1 | 1 | 1 | | | 1 | | | | | | | |
| ១៩ | ព្រៃវែង | | | | | | | | | | | | | | |
| ២០ | ស្វាយរៀង | 2 | 4 | 3 | 1 | | 3 | 3 | | | | | | | |
| ២១ | រតនៈគិរី | | | | | | | | | | | | | | |
| ២២ | មណ្ឌលគិរី | | | | | | | | | | | | | | |
| ២៣ | កោះកុង | | | | | | | | | | | | | | |
| ២៤ | កំពង់ធំ | | | | | | | | | | | | | | |
| ២៥ | ឧត្តរមានជ័យ | | | | | | | | | | | | | | |
| ២៦ | ON ផ្ទៃប្រទេស | 6 | 18 | 6 | 2 | | 16 | 3 | 3 | | | | | | |
| | **សរុបរួម** | 65 | 223 | 78 | 63 | 36 | 124 | 58 | 20 | | | | | | |

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | មាត្រា២៦ =(២៨៤) សញ្ជារកម្ម: ករណីបង្ក្រាប | ជនរងគ្រោះ ≥១៨ | ជនល្មើស ប | ជនល្មើស ស | សញ្ជារកម្ម (មានអនីតិជន): ករណីបង្ក្រាប | ជនរងគ្រោះ <១៥ | ជនរងគ្រោះ ១៥-១៧ | ជនរងគ្រោះ ≥១៨ | ជនល្មើស ប | ជនល្មើស ស |
|---|---|---|---|---|---|---|---|---|---|---|---|
| ១ | នាយកដ្ឋាន | ៤ | ១៧ | ២ | ៤ | ១ | | ២ | ២ | | ១ |
| ២ | រាជធានីភ្នំពេញ | ៣ | ៤១ | ២ | ២ | | | | | | |
| ៣ | សៀមរាប | ១ | ៤ | | ៣ | | | | | | |
| ៤ | បន្ទាយមានជ័យ | ២ | ១៤ | ១ | ១ | | | | | | |
| ៥ | កណ្តាល | | | | | | | | | | |
| ៦ | បាត់ដំបង | | | | | | | | | | |
| ៧ | ព្រះសីហនុ | ១ | ៤ | | ១ | | | | | | |
| ៨ | កំពង់ឆ្នាំង | | | | | | | | | | |
| ៩ | កំពង់ចាម | | | | | | | | | | |
| ១០ | កំពង់ស្ពឺ | | | | | | | | | | |
| ១១ | ព្រះវិហារ | | | | | | | | | | |
| ១២ | កំពត | | | | | | | | | | |
| ១៣ | ស្ទឹងត្រែង | | | | | | | | | | |
| ១៤ | កែប | | | | | | | | | | |
| ១៥ | ក្រចេះ | | | | | | | | | | |
| ១៦ | តាកែវ | | | | | | | | | | |
| ១៧ | ប៉ៃលិន | | | | | | | | | | |
| ១៨ | ពោធិ៍សាត់ | | | | | | | | | | |
| ១៩ | ព្រៃវែង | | | | | | | | | | |
| ២០ | ស្វាយរៀង | ១ | ៣ | ២ | | | | | | | |
| ២១ | រតនៈគិរី | | | | | | | | | | |
| ២២ | មណ្ឌលគិរី | | | | | | | | | | |
| ២៣ | កោះកុង | | | | | | | | | | |
| ២៤ | កំពង់ធំ | | | | | | | | | | |
| ២៥ | ឧត្តរមានជ័យ | | | | | | | | | | |
| ២៦ | ON ផ្ទៃប្រទេស | ៣ | ១៥ | ១ | ២ | | | | | | |
| | **សរុបរួម** | 15 | 98 | 8 | 13 | 1 | | 2 | 2 | | 1 |

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | មាត្រា២៧ =(២៨៨) សញ្ជារកម្ម (ស្ពានទម្ងន់ទោស): ករណីបង្ក្រាប | ជនរងគ្រោះ <១៥ | ជនរងគ្រោះ ១៥-១៧ | ជនរងគ្រោះ ≥១៨ | ជនល្មើស ប | ជនល្មើស ស | មាត្រា២៨ =(២៨៩) សញ្ជារកម្ម (ទាក់ទងនឹងពេស្យាចារកុមារ): ករណីបង្ក្រាប | ជនរងគ្រោះ <១៥ | ជនរងគ្រោះ ១៥-១៧ | ជនរងគ្រោះ ≥១៨ | ជនល្មើស ប | ជនល្មើស ស |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | នាយកដ្ឋាន | | | | | | | ១ | | ១៣ | ៧ | ៥ | ១ |
| ២ | រាជធានីភ្នំពេញ | | | | | | | ២ | ១ | ៤ | ៥ | | ២ |
| ៣ | សៀមរាប | | | | | | | | | | | | |
| ៤ | បន្ទាយមានជ័យ | | | | | | | | | | | | |
| ៥ | កណ្តាល | | | | | | | ១ | ១ | ១ | | ១ | ១ |
| ៦ | បាត់ដំបង | | | | | | | | | | | | |
| ៧ | ព្រះសីហនុ | | | | | | | | | | | | |
| ៨ | កំពង់ឆ្នាំង | | | | | | | | | | | | |
| ៩ | កំពង់ចាម | | | | | | | | | | | | |
| ១០ | កំពង់ស្ពឺ | | | | | | | | | | | | |
| ១១ | ព្រះវិហារ | | | | | | | | | | | | |
| ១២ | កំពត | | | | | | | | | | | | |
| ១៣ | ស្ទឹងត្រែង | | | | | | | | | | | | |
| ១៤ | កែប | | | | | | | | | | | | |
| ១៥ | ក្រចេះ | | | | | | | | | | | | |
| ១៦ | តាកែវ | | | | | | | | | | | | |
| ១៧ | ប៉ៃលិន | | | | | | | | | | | | |
| ១៨ | ពោធិ៍សាត់ | | | | | | | | | | | | |
| ១៩ | ព្រៃវែង | | | | | | | | | | | | |
| ២០ | ស្វាយរៀង | | | | | | | | | | | | |
| ២១ | រតនៈគិរី | | | | | | | | | | | | |
| ២២ | មណ្ឌលគិរី | | | | | | | | | | | | |
| ២៣ | កោះកុង | | | | | | | | | | | | |
| ២៤ | កំពង់ធំ | | | | | | | | | | | | |
| ២៥ | ឧត្តរមានជ័យ | | | | | | | | | | | | |
| ២៦ | ON ផ្ទៃប្រទេស | ១ | | | ១ | | ១ | | | | | | |
| | **សរុបរួម** | 1 | | | 1 | | 1 | 4 | 2 | 18 | 12 | 6 | 4 |

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | មាត្រា៣២ =(២៩៣) | | | | | | មាត្រា៣៩ | | | | | | មាត្រា៤១ | | | | | | មាត្រា៤២ | | | | | មាត្រា៤៣ =(២៤៦) | | | | | ជនរងគ្រោះ បញ្ជូនទៅ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ការផ្តល់ទីកន្លែង សម្រាប់ធ្វើពេស្យាចារ | | | | | | រូបភាព និង សម្ភារៈអាសអាភាស | | | | | | រូបភាព និង សម្ភារៈអាសអាភាសនៃកុមារ | | | | | | អំពើរួមភេទជាមួយអនីតិជន អាយុក្រោម១៥ឆ្នាំ | | | | | អំពើអាសប្រឆាំងនឹងអនីតិជន អាយុក្រោម១៥ឆ្នាំ (ប្រទូសកេរខ្មាស) | | | | | | | |
| | | ករណីប្រព្រឹត្ត | ជនរងគ្រោះ | | | ជនល្មើស | | ករណីប្រព្រឹត្ត | ជនរងគ្រោះ | | | ជនល្មើស | | ករណីប្រព្រឹត្ត | ជនរងគ្រោះ | | | ជនល្មើស | | ករណីប្រព្រឹត្ត | ជនរងគ្រោះ | | ជនល្មើស | | ករណីប្រព្រឹត្ត | ជនរងគ្រោះ | | ជនល្មើស | | | | |
| | | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | 18 | ប | ស | | -15 | 15-17 | ប | ស | | -15 | 15-17 | ប | ស | សដ | អក | គ្រស |
| 1 | នាយកដ្ឋាន | | | | | | | | | | | | | | | | | | | | | | | | 2 | 19 | 13 | 2 | | 70 | | 3 |
| 2 | រាជធានីភ្នំពេញ | 1 | | | 6 | | 1 | | | | | | | 3 | 1 | | | 3 | | 8 | 8 | | 8 | | 2 | 2 | | 2 | | 56 | | 12 |
| 3 | សៀមរាប | | | | | | | | | | | | | | | | | | | | | | | | 2 | 3 | | | | 6 | | 1 |
| 4 | បន្ទាយមានជ័យ | | | | | | | | | | | | | | | | | | | 1 | 1 | | 1 | | 2 | 2 | | 2 | | | | 17 |
| 5 | កណ្តាល | | | | | | | | | | | | | | | | | | | | | | | | 1 | 1 | | 1 | | | | 3 |
| 6 | បាត់ដំបង | | | | | | | 1 | | | 1 | 1 | | | | | | | | 4 | 6 | 2 | 4 | | 1 | 1 | | 1 | | | | 10 |
| 7 | ព្រះសីហនុ | | | | | | | | | | | | | | | | | | | 2 | 2 | | 2 | | 1 | 2 | 1 | 2 | | 4 | | 5 |
| 8 | កំពង់ឆ្នាំង | 1 | | | 4 | 1 | | | | | | | | | | | | | | 1 | 1 | | 1 | | | | | | | | | 5 |
| 9 | កំពង់ចាម | | | | | | | | | | | | | | | | | | | 2 | 2 | | 2 | | 2 | 2 | | 2 | | | | 4 |
| 10 | កំពង់ស្ពឺ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 11 | ព្រះវិហារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 12 | កំពត | | | | | | | | | | | | | | | | | | | 3 | 4 | | 3 | | | | | | | | | 4 |
| 13 | ស្ទឹងត្រែង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 14 | កែប | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 15 | ក្រចេះ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 16 | តាកែវ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 17 | ប៉ៃលិន | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 18 | ពោធិសាត់ | | | | | | | | | | | | | | | | | | | 1 | 1 | | 1 | | | | | | | | | 1 |
| 19 | ព្រៃវែង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 20 | ស្វាយរៀង | | | | | | | | | | | | | | | | | | | 1 | 1 | | 1 | | | | | | | | | 4 |
| 21 | រតនៈគិរី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 22 | មណ្ឌលគិរី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 23 | កោះកុង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 24 | កំពង់ធំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 25 | ឧត្តរមានជ័យ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 26 | ត្បូងឃ្មុំ | | | | | | | | | | | | | | | | | | | 1 | 1 | | 1 | | 1 | 1 | | 1 | | 2 | | 16 |
| | **សរុបរួម** | 2 | | | 10 | 1 | 1 | 1 | | | 1 | 1 | | 3 | 1 | | | 3 | | 24 | 27 | 2 | 24 | | 14 | 33 | 14 | 15 | | 138 | | 85 |

**សដៈ មន្ទីរសង្គមកិច្ចរាជធានី-ខេត្ត** អកៈ អង្គការក្រៅរដ្ឋាភិបាល គ្រសៈ គ្រួសារ ឬ អាណាព្យាបាល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...០១...គភក**

ចូល ០៦៧ 11.7.13 16.0

# គោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល

# ស្តីពី

# ការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរពលករទេសន្តរប្រវេសន៍កម្ពុជា

ដោយមើលឃើញថាៈ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រជាជនយើងបាននាំគ្នាធ្វើចំណាកស្រុកនិងឆ្លងដែនទៅធ្វើការនៅប្រទេសក្រៅយ៉ាងគគ្រឹកគគ្រេង មានទាំងទៅតាមប្រព័ន្ធផ្លូវការ និងទាំងតាមប្រព័ន្ធមិនផ្លូវការដោយអាណាធិបតេយ្យ និងពុំមានការគ្រប់គ្រងច្បាស់លាស់ ។

នៅក្នុងសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការគ្រប់គ្រងទេសន្តរប្រវេសន៍ ដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិដឹកនាំការបង្ក្រាបអំពើជួញដូរមនុស្ស ការរត់ពន្ធ ការធ្វើអាជីវកម្មពលកម្មលើមនុស្ស និងអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ (ប.ជ.រ.ព.ភ) កាលពីថ្ងៃទី ២៦ ដល់ទី២៨ ខែមិនា ឆ្នាំ២០១៣ នៅក្រសួងមហាផ្ទៃ យើងបានឯកភាពគ្នាហើយថាៈ ចំណាកស្រុក ឬទេសន្តរប្រវេសន៍ គឺជាចរន្តធម្មជាតិរបស់មនុស្សដែលព្យាយាមត្រាច់ចរ ដើម្បីស្វែងរកភាពរីកចម្រើនក្នុងជីវិតរស់នៅ ។ ប៉ុន្តែចំណុចដែលគួរឲ្យព្រួយបារម្ភក្នុងពេលបច្ចុប្បន្ននេះ គឺ <u>ភាពរងគ្រោះរបស់ប្រជាពលរដ្ឋក្នុងពេលធ្វើទេសន្តរប្រវេសន៍ និងភាពអាណាធិបតេយ្យនៃការធ្វើចំណាកស្រុក ចាំបាច់ត្រូវគ្រប់គ្រង និងការពារ</u> ។

ចំណាកស្រុក និងបញ្ហាទេសន្តរប្រវេសន៍បានក្លាយជារបៀបវារៈមួយសម្រាប់ការគិតគូរក្នុងក្របខ័ណ្ឌគោលនយោបាយជាតិ និងអន្តរជាតិ ដែលប្រទេសទាំងឡាយលើសកលលោកកំពុងតែប្រឈមនឹងការរកដំណោះស្រាយដែលមានប្រសិទ្ធិភាព ជាពិសេសដើម្បីសម្របសម្រួលឲ្យមានភាពសុខដុម និងកិច្ចសហការល្អរវាងប្រទេសបញ្ជូន និងប្រទេសទទួល ពោលគឺប្រទេសដែលមានកម្លាំងពលកម្ម និងប្រទេសដែលត្រូវការកម្លាំងពលកម្ម ។ កិច្ចការនេះ ត្រូវការភាពឈ្លាសវៃ និងអត់ធ្មត់ក្នុងការដោះស្រាយ ព្រោះថា ជាការប្រកួតប្រជែងផ្នែកនយោបាយសេដ្ឋកិច្ច និងសង្គម ដែលប្រទេសនីមួយៗ ចាំបាច់ត្រូវការពារផលប្រយោជន៍ជាតិ និងប្រជាជនរៀងៗខ្លួន ។ ទន្ទឹមនឹងនោះ ជនល្មើសតែងប្រើប្រាស់ភាពខ្វះចន្លោះនៃកិច្ចសហការ និងការអនុវត្តន៍ច្បាប់ ដើម្បីកេងយកផលចំណេញពីគ្រប់តំណាក់កាលនៃការធ្វើទេសន្តរប្រវេសន៍ ធ្វើឲ្យពលករទទួលរងនូវការខាតបង់ ការឈឺចាប់ និងការលំបាកច្រើនរាប់មិនអស់ ក្នុងនោះ

ក៏មានទាំងការជួញដូរមនុស្ស ការរត់ពន្ធមនុស្ស ការរំលោភបំពានសិទ្ធិ និងការកេងប្រវ័ញ្ចគ្រប់រូបភាពលើពលករផងដែរ ។ ការឈឺចាប់ និងការខាតបង់របស់ពលករ ក៏ជាការឈឺចាប់ និងការខាតបង់របស់រាជរដ្ឋាភិបាលដែរ ព្រោះពលករគឺជាធនធានសេដ្ឋកិច្ច និងសង្គមដ៏មានតម្លៃ ជាមនុស្សពេញវ័យ ពេញកម្លាំងការងារ ដែលចាំបាច់ត្រូវរក្សា និងអភិវឌ្ឍកម្លាំងពលកម្មទាំងនេះ សម្រាប់ផលិតកម្ម និងសេវាកម្មក្នុងស្រុកដែលកំពុងតែខ្វះខាត ។

យើងចង់ឲ្យប្រជាពលរដ្ឋមានការងារធ្វើ មានមុខរបរសមរម្យ និងខិតខំលើកកម្ពស់ជីវភាពនៅក្នុងស្រុកឲ្យអស់លទ្ធភាព ដោយចាត់ទុកការធ្វើចំណាកស្រុកជាជម្រើសចុងក្រោយ និងគ្រាន់តែជាតំណាក់កាលបណ្តោះអាសន្នប៉ុណ្ណោះ ។

ដូចនេះ **ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា** ខ្ញុំសូមអំពាវនាវដល់ថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អាជ្ញាធរ និងសមត្ថកិច្ចគ្រប់ថ្នាក់ទាំងអស់ គប្បីយកចិត្តទុកដាក់អនុវត្តភារកិច្ចតាមមុខសញ្ញារៀងៗខ្លួន និងសហការគ្នាឲ្យបានល្អតាមទិសដៅតែមួយ គឺ៖ "

រួមគ្នាកសាងនូវបរិស្ថានល្អ សម្រាប់ជាជម្រើសជូនប្រជាពលរដ្ឋឲ្យអាចរស់នៅក្នុងស្រុកក៏ល្អប្រសើរ បើចេញទៅធ្វើការងារនៅក្រៅប្រទេសក៏ថ្លៃថ្នូរ និងមានសុវត្ថិភាព"

និងគប្បីជម្រុញការយកចិត្តទុកដាក់ធ្វើឲ្យសម្រេច នូវភារកិច្ចជាគន្លឹះដូចខាងក្រោម៖

១. ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គប្បី៖

- ផ្តល់នូវការសម្របសម្រួលតាមនីតិវិធីរៀបរយ សមស្រប ងាយស្រួល និងមានលក្ខណៈជាប្រព័ន្ធ ដែលធានាដល់ការការពារសិទ្ធិ និងផលប្រយោជន៍ប្រកបដោយសមធម៌ជូនពលករ ពលការិនី ក៏ដូចជានិយោជក និងរវាងប្រទេសបញ្ជូន និងប្រទេសទទួល ។
- ជម្រុញការដោះស្រាយបញ្ហាដែលសេសសល់ ពាក់ព័ន្ធនឹងពលករ ពលការិនីដែលបានរងគ្រោះក្នុងអំឡុងពេលធ្វើទេសន្តរប្រវេសន៍ការងារនៅក្រៅប្រទេស និងដែលកំពុងប្រឈមនឹងការមិនទទួលខុសត្រូវពីក្រុមហ៊ុនដែលត្រូវបានបិទ ឬផ្អាក ឬថៅកែរត់ចោលក្រុមហ៊ុនជាដើម ដោយសហការផ្តល់ព័ត៌មាន ឯកសារពាក់ព័ន្ធទៅតុលាការ ដើម្បីផ្តន្ទាទោសជនខិលខូច និងរកយុត្តិធម៌ជូនជនរងគ្រោះ ព្រមទាំងទាមទារសំណងតាមនីតិវិធី ។
- សម្របសម្រួលជាមួយសមាគមទីភ្នាក់ងារជ្រើសរើសពលករ ដើម្បីពិនិត្យបញ្ចុះតម្លៃសេវាដែលត្រូវកាត់ពីពលករទៅធ្វើការនៅប្រទេសថៃពី១០ខែ(២ម៉ឺនបាត) ទៅ៦ខែ (១ម៉ឺនពីរពាន់បាត) វិញ ។
- បញ្ជូន ឈ្មោះ និងអាសយដ្ឋានក្រុមហ៊ុនជ្រើសរើសពលករដែលទទួលការអនុញ្ញាតិទៅអាជ្ញាធរដែនដីពាក់ព័ន្ធឲ្យបានជ្រាប និងផ្សព្វផ្សាយឲ្យបានទូលំទូលាយជូនប្រជាពលរដ្ឋ រួមជាមួយឯកសារបញ្ជាក់និងលក្ខខ័ណ្ឌនានា ដែលជាការទទួលខុសត្រូវរបស់ក្រុមហ៊ុនចំពោះរដ្ឋ និងពលករ ដើម្បីជៀសវាងការក្លែងបន្លំពីជនខិលខូច។

- ឲ្យក្រុមហ៊ុនបញ្ជូនបញ្ជីឈ្មោះ រូបថតនិងអត្តសញ្ញាណរបស់ភ្នាក់ងារឬបុគ្គលិករបស់ខ្លួនដែលមានភារកិច្ចចុះជ្រើសរើសពលករក្នុងមូលដ្ឋានដែលមានការអនុញ្ញាត ទៅអាជ្ញាធរមូលដ្ឋានសាម៉ីឲ្យចុះបញ្ជី និងផ្សព្វផ្សាយ ។ រាល់ការផ្លាស់ប្តូរត្រូវជូនពត៌មានជាថ្មី ។
- ជម្រុញការតាមដាន ត្រួតពិនិត្យ វាយតម្លៃ ទៅលើនីតិវិធី និងការអនុវត្តន៍របស់ក្រុមហ៊ុនដែលមានភារកិច្ចជ្រើសរើស បណ្តុះបណ្តាល បញ្ជូន ដើម្បីធានាសុវត្ថិភាព និងផលប្រយោជន៍ពលករកម្ពុជា និងដើម្បីដោះស្រាយបញ្ហាឲ្យបានទាន់ពេលវេលា ។
- សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ តាមដានការបើកកន្លែងបណ្តុះបណ្តាលមួយចំនួន ដែលសង្ស័យថា បោកប្រាស់យុវជន យុវនារី អំពីការធានារកការងារនៅប្រទេសកូរ៉េ ជប៉ុន ថៃ ដែលមានបៀវត្សរ៍ខ្ពស់ ដើម្បីប្រមូលប្រាក់ រួចបិទសាលា ឬប្តូរឈ្មោះ ប្តូរទីតាំងដើម្បីរកស៊ីជាថ្មី ។ មុខសញ្ញានេះ គប្បីរកឲ្យឃើញ និងផ្តន្ទាទោសតាមច្បាប់ ។
- សហការជាមួយក្រសួងពាក់ព័ន្ធ ពិនិត្យ និងជម្រុញការផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិលេខ ១៨៩ ដែលស្តីពីការងារសមរម្យសម្រាប់អ្នកធ្វើការតាមផ្ទះ ដើម្បីជាមូលដ្ឋានគតិយុត្តិសម្រាប់ការពារពលករ និងលិខិតូបករណ៍ដទៃទៀតដែលពាក់ព័ន្ធនឹងការគោរព សិទ្ធិពលករទេសន្តរប្រវេសន៍ និងក្រុមគ្រួសារ ។

២. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ គប្បីពិនិត្យលទ្ធភាពក្នុងការបង្កើនចំនួនមន្ត្រីឲ្យទទួលបន្ទុកកិច្ចការពលករទេសន្តរប្រវេសន៍ ជាពិសេសក្នុងប្រទេសដែលមានពលករកម្ពុជាកំពុងធ្វើការងារនៅទីនោះ និង សហការជាមួយក្រសួងពាក់ព័ន្ធដើម្បីការពារពលករពីការរំលោភបំពាន ការជួញដូរ និងការកេងប្រវ័ញ្ចគ្រប់រូបភាព ។

៣. បណ្តាក្រសួង ស្ថាប័នដែលត្រូវបង្កើតការងារ និងមុខរបរជូនប្រជាពលរដ្ឋ មានជាអាទិ៍ ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងទេសចរណ៍ ក្រសួងកសិកម្ម និងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត គប្បី៖

- ជម្រុញឲ្យមានកិច្ចសហការល្អជាមួយរោងចក្រ សហគ្រាស ក្រុមហ៊ុន ក្នុងការកសាងបរិស្ថាន និងបរិយាកាសការងារល្អ ដែលផ្តល់នូវផាសុខភាព និងភាពសប្បាយរីករាយក្នុងការងារ
- ពិនិត្យលទ្ធភាពក្នុងការផ្តល់នូវការលើកទឹកចិត្ត ដល់អ្នកប្រឹងប្រែងធ្វើការងារ ពង្រឹងវិន័យ និងសីលធម៌វិជ្ជាជីវៈ យកចិត្តទុកដាក់ដល់ការស្នាក់នៅ ហូបចុក ការថែទាំសុខភាពអនាម័យ និងបៀវត្សរ៍សមរម្យ ដើម្បីឲ្យពលករនឹងនចិត្ត ទាក់ទាញពលករខ្មែរនៅក្រៅប្រទេសវិលត្រឡប់មកធ្វើការងារក្នុងស្រុក និងកាត់បន្ថយលំហូរចេញកម្លាំងពលកម្ម ។
- ពង្រីកការផ្សព្វផ្សាយ ឲ្យបានទូលំទូលាយអំពីពត៌មានទីផ្សារក្នុងស្រុក ដែលមានលក្ខខ័ណ្ឌល្អប្រសើរ ដើម្បីប្រជាពលរដ្ឋមានមូលដ្ឋានក្នុងការសម្រេចចិត្ត ជ្រើសរើសការងារដែលខ្លួនពេញចិត្ត និងពិនិត្យឡើងវិញ ឬផ្អាកជាបន្ទាន់ រាល់ការផ្សព្វផ្សាយបំផ្លើសដើម្បីទាក់ទាញឲ្យទៅធ្វើការងារក្រៅប្រទេស ដោយគ្មានការទទួលខុសត្រូវ ។

៤. ក្រសួងមហាផ្ទៃ ដែលរាប់ទាំងរដ្ឋបាលស៊ីវិល កងកម្លាំងនគរបាល ជំនាញពាក់ព័ន្ធនឹងការផ្តល់លិខិតបទដ្ឋាន អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន...។ល។ គប្បី៖

- ពង្រឹងការអនុវត្តន៍ និងពិនិត្យឡើងវិញនូវរបៀបរបបការងារដើម្បីកាត់បន្ថយភាពសាំញ៉ាំក្នុងនីតិវិធី កាត់បន្ថយភ្នាក់ងារកណ្តាល ដែលនាំឲ្យមានការចំណាយកម្រៃខ្ពស់ និងប្រើពេលវេលាយូរ ។
- ផ្តល់ការណែនាំដល់អាជ្ញាធរមូលដ្ឋាននូវនីតិវិធីសម្រាប់ការគ្រប់គ្រងភាពចល័តរបស់ប្រជាពលរដ្ឋ កសាងបញ្ជីចេញចូល និងទំនាក់ទំនងសាកសួរព័ត៌មាន អប់រំ ជៀសវាងការចាញ់បោកការអូសទាញរបស់មេខ្យល់ ។
- ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការកសាងបណ្តាញសុវត្ថិភាពភូមិ ឃុំ និងការកសាងផែនការវិនិយោគឃុំសង្កាត់ ដែលឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ ។
- ពង្រឹងនីតិវិធីក្នុងខេត្តសំចត ដើម្បីគ្រប់គ្រងប្រជាជនចល័តមកពីខេត្តដទៃ ដោយចុះបញ្ជី និងត្រួតពិនិត្យឲ្យបានដិតដល់ យកចិត្តទុកដាក់សាកសួរអំពីគោលដៅនៃការធ្វើ ចំណាកស្រុកដើម្បីធ្វើការអប់រំ និងទប់ស្កាត់ការឆ្លងដែនដោយខុសច្បាប់ ។

៥. គណៈកម្មាធិការជាតិ គ.ជ.អ.ប ពិនិត្យលទ្ធភាពក្នុងការបង្កើតការិយាល័យច្រកចេញចូលតែមួយរួមទាំងការផ្តល់លិខិតឆ្លងដែននៅតាមបណ្តាខេត្តគោលដៅ ដើម្បីផ្តល់សេវាជាកញ្ចប់ជូនប្រជាពលរដ្ឋ ដែលឆាប់រហ័ស និងមានតម្លៃថោកតាមការកំណត់ ជាពិសេសសេវាកម្មពាក់ព័ន្ធនឹងការរកការងារធ្វើនៅក្រៅប្រទេស ដោយផ្សារភ្ជាប់ទំនាក់ទំនងសហការជាមួយមជ្ឈមណ្ឌលសេវាការងាររបស់ថៃដែលគ្រោងនឹងបង្កើតដែរនោះ ។

៦. សមត្ថកិច្ចព្រំដែន ទាំងនគរបាល ទាំងយោធា ត្រូវសហការគ្នាក្នុងការពង្រឹងការត្រួតពិនិត្យការចេញចូលតាមច្រករបៀង និងគប្បីពិនិត្យលទ្ធភាពបង្កើតជាក្រុមការងារចម្រុះមួយដែលមានស្ថាប័ន និងអង្គភាពគន្លឹះពាក់ព័ន្ធ មានភារកិច្ចគ្រប់គ្រងលំហូរពលករក្នុងគោលដៅការពារអាយុជីវិត សិទ្ធិ និងផលប្រយោជន៍របស់ពលរដ្ឋកម្ពុជា ជាពិសេស យកចិត្តទុកដាក់ចំពោះផលប៉ះពាល់ទៅលើស្ត្រី និងកុមារក្នុងដំណើរការនៃការធ្វើទេសន្តប្រវេសន៍ ។

៧. លើសពីនេះទៅទៀត ក្រសួងមហាផ្ទៃ ក្រសួងពត៌មាន ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងធម្មការសាសនា ក៏ដូចជាអាជ្ញាធរដែនដី និងអង្គការសង្គមស៊ីវិលទាំងអស់ គប្បីរួមសហការគ្នាផ្សព្វផ្សាយនូវពត៌មានជាក់លាក់ គោលការណ៍ គោលនយោបាយ បទដ្ឋាន និងនីតិវិធីទាំងឡាយ ឲ្យប្រជាពលរដ្ឋបានដឹងដូចៗគ្នា និងជម្រុញការអនុវត្តឲ្យស៊ីសង្វាក់គ្នាដើម្បីផ្តល់ភាពជឿជាក់ពីប្រជាពលរដ្ឋ ។

៨. គណៈកម្មាធិការជាតិ ប.ជ.រ.ព.ភ គប្បី៖

- ពង្រឹងកិច្ចសហការផ្ទៃក្នុង រវាងក្រសួង ស្ថាប័នពាក់ព័ន្ធឲ្យបានជិតស្និទ្ធ និងជម្រុញឲ្យមានកិច្ចព្រមព្រៀង ឬអនុស្សរណៈ ជាមួយប្រទេស ពាក់ព័ន្ធ ដោយមានខ្លឹមសារគ្រប់គ្រាន់ នីតិវិធីច្បាស់លាស់ប្រកបដោយការទទួលខុសត្រូវ ដើម្បីធានាដល់ការការពារពលករផង និងកិច្ចសហប្រតិបត្តិការល្អផង ជាពិសេសជាមួយស្ថានទូតកម្ពុជានៅក្នុងប្រទេសពាក់ព័ន្ធ ។
- ជម្រុញឲ្យក្រុមការងារទេសន្តរប្រវេសន៍ ដែលមានក្រសួងមហាផ្ទៃ និងក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈជាស្នូល ពិនិត្យលទ្ធភាពក្នុងការកសាងនីតិវិធីសមស្រប និងកិច្ចសហការជាមួយប្រទេសពាក់ព័ន្ធ ដើម្បីការពារ និងគ្រប់គ្រងពលករដែលស្វែងរកការងារមិនតាមប្រព័ន្ធរៀបរយដែលមានបច្ចុប្បន្ន និងបង្វែរការផ្តល់ភាពស្របច្បាប់ក្រោយពេលចូលទៅធ្វើការងារដោយខុសច្បាប់ ទៅជាការធានាភាពស្របច្បាប់ តាំងពីមុនពេលឆ្លងដែន។
- ជម្រុញការតាមដានត្រួតពិនិត្យ វាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍នេះ និងរាយការណ៍ជូនគណៈរដ្ឋមន្ត្រីអំពីភាពរីកចំរើន ។

ទទួលបានគោលការណ៍ណែនាំនេះ សូមឯកឧត្តម លោកជំទាវ ប្រធានគណៈកម្មាធិការ រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងអង្គភាពពាក់ព័ន្ធទាំងអស់ យកចិត្តទុកដាក់អនុវត្តឲ្យមានប្រសិទ្ធភាពចាប់ពីពេលនេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-គ្រប់ខុទ្ទកាល័យក្រសួងស្ថាប័ន
-គ្រប់សាលារាជធានីខេត្ត
-ឯកសារ កាលប្បវត្តិ

# សកម្មភាពគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ត







សិក្ខាសាលាគណៈកម្មាធិការជាតិ ស្ដីពីការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ការងារ





កិច្ចប្រជុំវិសាមញ្ញរបស់គណៈកម្មាធិការជាតិ
ពង្រឹងសកម្មភាព ប.ជ.រ.ព.ត















ប្រជុំពិភាក្សា ស្តីពីការរៀបចំព្រះរាជក្រឹត្យ

ដើម្បីបង្កើតគណៈកម្មាធិការជាតិ (គ.ជ.ប.ជ)








ការសម្ពោធ
ដាក់ឱ្យ ប្រើប្រាស់សៀវភៅ
បណ្ដុះបណ្ដាល ស្ដីពី
ការស៊ើបអង្កេត និងផ្ដន្ទាទោស
អំពើរត់ពន្ធជនទេសន្តរប្រវេសន៍

និងការអនុវត្តគម្រោង
CAU ការប្រមូលវិភាគទិន្នន័យ
PATROL
ពង្រឹកសមត្ថភាពអ្នកជំនាញ
ទំនាក់ទំនងព្រំដែន
PIU អង្គភាពចារកម្មកំពង់ផែ






# សកម្មភាពរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិដឹកនាំ ប.ជ.រ.ព.ត





## កិច្ចប្រជុំពិភាក្សាជម្រុញសកម្មភាពក្រុមការងារ





# សកម្មភាពរបស់ក្រុមការងារលេខាធិការដ្ឋានជាតិ

## សកម្មភាពឆ្លើយតបគោលការណ៍ណែនាំ របស់រាជរដ្ឋាភិបាល






## សកម្មភាពទស្សនៈកិច្ចសិក្សាស្វែងយល់ អំពីសកម្មភាពក្រុមហ៊ុនជ្រើសរើសពលករ





## ការរៀបចំឯកសារផ្សព្វផ្សាយ សម្រាប់ការងារបង្ការ ទប់ស្កាត់





កិច្ចសហការអង្គការ ជាមួយ
អគ្គស្នងការនគរបាលជាតិ





ការរៀបចំឯកសារ
បណ្តុះបណ្តាល
ជំនាញប្រឆាំង
ការជួញដូរមនុស្ស

ការពិភាក្សាលើការងារ សហការរវាងអង្គការដៃគូ ជាមួយលេខាធិការដ្ឋានជាតិ



កិច្ចសហការរៀបចំឯកសារបង្ការ ទប់ស្កាត់ តាមរថយន្តក្រុង និងព្រលានយន្តហោះ



កិច្ចពិភាក្សាលើលទ្ធផលនៃការធ្វើទស្សនៈកិច្ចរបស់ក្រុមការងារទេសន្តរប្រវេសន៍



# ការបណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់






ពិភាក្សាពិគ្រោះយោបល់ អំពីក្របខណ្ឌច្បាប់ ពាក់ព័ន្ធនឹងវិធីស្រាវជ្រាវ ស៊ើបអង្កេតដោយសម្ងាត់



កិច្ចសហការបង្កើតក្រុមស្រាវជ្រាវ
ច្បាប់ថ្នាក់តំបន់
ទាក់ទងទេសចរណ៍ផ្លូវភេទលើកុមារ





សកម្មភាពចុះវិភាគរឿងក្តី
ទាក់ទងការជួញដូរមនុស្ស
នៅតាមបណ្តាតុលាការខេត្ត





វគ្គបណ្តុះបណ្តាល
ពង្រឹងសមត្ថភាព
អំពីច្បាប់ជាតិ
និងអន្តរជាតិ
ពាក់ព័ន្ធនឹងការ
ការពារសិទ្ធិកុមារ

# ឯកសារផលិតដោយ

# លេខាធិការដ្ឋាន

# នៃ

# គណៈកម្មាធិការជាតិដឹកនាំ

# ប.ជ.រ.ព.ភ




Kingdom of Cambodia
Nation, Religion, King
REPORT
ON
THE ACTIVITIES AND RESULTS OF THE SUPPRESSION OF HUMAN TRAFFICKING, SMUGGLING, LABOR EXPLOITATION AND SEXUAL EXPLOITATION OF WOMEN AND CHILDREN
FOR 2010 AND
2011 GOALS




UNIAP
UNODC


Kingdom of Cambodia
Nation Religion King
NATIONAL PLAN OF ACTION
on the
Suppression of Human Trafficking, Smuggling, Labour, and Sexual Exploitation (S.T.S.L.S.)
2011-2013
UNIAP
UNODC




UN WOMEN


Kingdom of Cambodia
Nation Religion King
Migration Working Group
Report 2012
UN WOMEN



ឧបត្ថម្ភដោយ:

USAID FROM THE AMERICAN PEOPLE

WINROCK INTERNATIONAL

UNIAP United Nations Inter-Agency Project on Human Trafficking

Somaly Mam FOUNDATION